“ អាសំឡីបានត្រូវរបួសធ្ងន់ “ អាព្រួញប្រកែកភ្លាម” យើងទាំងអស់ បានឃើញវារត់ទាំងចេញឈាមហូរស្រោចពេញខ្លួន” ។

“នេះជាកលល្បិចទៀត!” អាប្រាជ្ញនៅតែខំពន្យល់តទៅទៀត “អាស្វិតបាញ់វាត្រូវតែបន្តិចទេ ។ អញបានឃើញសំបុត្រដែលវាបានសរសេរដោយដៃផ្ទាល់របស់វា ។ បើប្រសិនជាពួកឯងចេះមើលឯងនឹងឃើញថា អាសំឡីបានរៀបចំគំរោងការក្បត់នេះជាមួយអាស្វិត ៖ គឺថាក្នុងពេលមានស្ថានភាពផុនដាប ហើយ ឱកាសហុចមកដល់ហើយ វានឹងឱ្យសញ្ញាសត្វទាំងអស់រត់ចេញ ដើម្បីទុកភូមិឱ្យខ្មាំងចូលបកកាន់កាប់ ។ សមមិត្ត ! គំរោងការនេះហៀបនឹងបានសំរេចទៅហើយ ។ អញជឿច្បាស់ថា វាប្រាកដជាឈ្នះ បើកុំតែបានរៀមច្បងបដិវត្តន៍របស់យើង គឺមិត្តឈ្មុះមកជួយទាន់ ។ តើឯងនៅចាំបានទេ ថាក្នុងពេលដែលអាស្វិតនិងគ្នាវាចូលមកដល់កណ្តាលភូមិ អាសំឡីរត់បះជើងហើយមានសត្វជាច្រើនរត់តាមក្រោយវា ! ហើយតើហ្វូងទាំងអស់គ្នានៅចាំទៀតទេថា ក្នុងពេលប្រចុជួនដែលភាពចលាចលបានកើតឡើងពេញទី ហើយក្នុងពេលដែលយើងហៀបតែនឹងចាញ់ អាស្វិតទៅហើយនោះស្រាប់តែឮសម្លេងមួយ



ស្រែកឡើងថា “ពួកមនុស្សត្រូវបរាជ័យ” នេះជាសម្លេងរបស់មិត្តឈ្មុះ ដែលខំស្រែកពញ្ញាក់សតិយើងព្រមទាំងស្ទុះទៅខាំជើងអាស្វិត ។ អញជឿថាហ្វូងទាំងអស់គ្នានៅចាំបានមែនទេ ? នេះជាពាក្យពន្យល់របស់អាប្រាជ្ញ ។ វាដើរចុះ ដើរឡើងបណ្តើរហាក់ដូចជាគិតអំពីអ្វីមួយ ។

ក្រោយពីបានស្តាប់ពាក្យឃោសនារបស់អាប្រាជ្ញមក សត្វទាំងឡាយហាក់ដូចជាចាំរឿងនោះឡើងវិញ ។ យ៉ាងណាមិញ វាទាំងអស់នឹកឃើញថាមានមួយពេលនោះ អាសំឡីបានរត់ចេញទៅក្រៅមែន ។ អាព្រួញនៅតែមិនអស់ចិត្ត ។ ទីបំផុតវានិយាយឡើងថា៖ “ អញមិនជឿថា អាសំឡី មានគំនិតក្បត់ទេ ។ ពិតមែនហើយថា ក្រោយពីពេលប្រយុទ្ធមក អាកប្បកិរិយារបស់វាបានផ្លាស់ប្តូរខ្លះ ។ តែអញនៅតែជឿថា វាជាមិត្តចិត្តមួយថ្លើមមួយរបស់យើងក្នុងពេលប្រយុទ្ធ” អាប្រាជ្ញឆ្លើយវិញភ្លាម ដោយសំដីមួយៗតែច្បាស់លាស់៖ “មិត្តឈ្មុះរៀមច្បងបដិវត្តន៍បានប្រាប់យើងច្រើនដងច្រើនគ្រាហើយ ថាអាសំឡីជាចារបុរសរបស់អាស្វិត តាំងពីយូរយារណាស់ហើយ ។ វាបានរួមគំនិតជាមួយអាស្វិតតាំងពីមុនបដិវត្តន៍មកម្ល៉េះ” ។

“ ឱ ! បើអញ្ចឹងមែនអញខុសហើយ ” អាព្រួញឆ្លើយកាត់ភ្លាម ៖ “ បើមិត្តឈ្មុះថាអញ្ចឹងមែន វាពិតជាត្រូវ ” ។

“ សមមិត្ត ! ត្រូវហើយ នេះបានពិតជាគំនិតសោបត្តិ ” អាប្រាជ្ញស្រែកឡើង ហើយសម្លក់ទៅអាព្រួញ ។ អាប្រាជ្ញបោះជំហានដើរទៅមុខ ក៏ប៉ុន្តែឈប់វិញ - នៅស្ងៀមបន្តិច - ហើយនិយាយទៀតថា ៖ “ អញចង់ប្រាប់ឲ្យឯងទាំងអស់ដឹងមុនឲ្យហើយថា ចាប់ពីថ្ងៃនេះទៅ ឯងរាល់គ្នាត្រូវបើកភ្នែកឲ្យធំៗ មុននឹងនិយាយអ្វីៗ ព្រោះអញជឿថាមុខជាមានគ្នីគ្នាអាសំឡីនៅបង្កប់ក្នុងចំណោមយើងនេះ! ” ។

បួនថ្ងៃក្រោយមក នៅរសៀលថ្ងៃមួយ អាឈ្មុះបានបញ្ជាឲ្យហៅសត្វទាំងអស់មកប្រជុំនៅទីធ្លា ។ លុះសត្វទាំងអស់មកជុំគ្នាហើយ អាឈ្មុះក៏ដើរចេញពីផ្ទះ ។ គេឃើញវាមានពាក់មេដាយ ២មួយគឺ “វីរបុរសថ្នាក់លេខ១” និង “វីរបុរសថ្នាក់លេខ២” នេះជាមេដាយដែលវាបំពាក់ខ្លួនឯង ។ ឆ្កែប្រាំបួនរត់ជុំវិញវា ស្រែកកញ្ជ្រៀវពីចម្ងាយ ធ្វើឲ្យសត្វទាំងឡាយព្រឺស្លុងខ្លួនគ្រប់ៗគ្នា ។ សត្វទាំងអស់អង្គុយចាំយ៉ាងស្ងៀមស្ងាត់ បានចិត្តពិភាល់ថាមុខជាមានរឿងអ្វីចម្លែកកើតឡើងហើយ ។



ដល់ហើយអាឈ្មុះឈរស្ងៀមបានទឹកមុខប៉ុងប៉ាត់សំឡឹងទៅបណ្ដាសត្វទាំងអស់ ។ បន្ទាប់មក ទើបវាបញ្ចេញសំឡេងយ៉ាងខ្លាំងគួរឲ្យព្រឺក្បាល ។ ក្រោយមកឆ្កែទាំងប្រាំបួនរត់យ៉ាងលឿនតម្រង់ទៅរកសត្វដែលកំពុងអង្គុយ ។ ដល់ហើយវាហាមាត់ត្រចាក់ខាំកជ្រូកទាំងបួនក្បាល - ជ្រូកស្រែកដោយភិតភ័យនិងឈឺចាប់ ។ វាខាំត្រចៀកហើយអូសអាជ្រូកបួនក្បាលនោះ យកមកដាក់នៅក្រោមជើង អាឈ្មុះ ។ ឈាមហូរស្រោកពីត្រចៀកជ្រូកទាំងបួន ។ ឆ្កែយកអណ្ដាតលិតឈាមទាំងកំហឹងនិងអន្ទះអន្ទែង ។

បន្ទាប់មក គេឃើញឆ្កែបីរត់យ៉ាងលឿនតម្រង់ទៅរកអាព្រួញ ។ ឃើញដូច្នោះហើយ សត្វទាំងអស់ស្រឡាំងកាំងភិតភ័យរន្ធត់គ្រប់ៗគ្នា ។ ភ្លាមនោះអាព្រួញលើកជើងមុខទាត់ចំអាឆ្កែមួយប៉ើងឡើងទៅលើ ហើយដាក់ជើងមកវិញសង្កត់វាផ្អប់នឹងដី ។ អាឆ្កែស្រែកញ៉េកៗ សុំសេចក្ដីមេត្តា - ចំណែកអាពីរទៀតរត់បាត់កន្ទុយ ។ អាព្រួញសម្លឹងមុខទៅរកអាឈ្មុះ ដូចជាចង់បានបញ្ជាថា តើវាគួរប្រល័យអាឆ្កែនេះឬក៏ត្រូវលែងឲ្យវារួចខ្លួន ។ ឃើញដូច្នោះ អាឈ្មុះប្រែទឹកមុខភ្លាម - ហើយបញ្ជាឲ្យលែងឆ្កែ ។ អាព្រួញបង្ហើបជើង - អាឆ្កែស្ទុះរត់ចេញដោយគ្រាំគ្រានិងស្រែកថ្ងូរដោយឈឺចាប់ ។

ភាពច្របូកច្របល់ក៏បាត់ទៅវិញ ។ អាជ្រូកទាំងបួនអង្គុយដោយសេចក្ដីញ័ររន្ធត់ - ទឹកមុខសម្ដែងនូវសេចក្ដីព្រួយបារម្ភ ហាក់ដូចជាមនុស្សមានទោស ។ អាឈ្មុះហៅជ្រូកទាំងបួនឱ្យចេញមកក្រៅ ហើយបញ្ជាឱ្យនិយាយប្រាប់អង្គប្រជុំអំពីកំហុសរបស់វា ។ ទាំងអស់គ្នាដឹងថា អាជ្រូកទាំងនេះហើយដែលបានជំទាស់នឹងគំនិតអាឈ្មុះដែលបញ្ជាឱ្យលុបសន្និសីទព្រឹកថ្ងៃអាទិត្យចោល ។ ដោយមិនបានគិតជាមុន ជ្រូកទាំងបួនក៏បានរៀបរាប់ប្រាប់អង្គប្រជុំថា វាបានជួបដោយលួចហាក់ជាមួយអា រំគី ហើយវាបានចូលដៃជាមួយអាសំឡីក្នុងការបំផ្លាញរោហាត់ខ្យល់ ។ ហើយនៅពេលថ្មីៗនេះទៀតវាបានរួមគំនិតជាមួយ អាសំឡីក្នុងការដណ្ដើមភូមិសម្រែងឱ្យពូយៀង ។ វាបន្ថែមទៀតថា ថ្ងៃមួយអាសំឡីបានខ្សឹបប្រាប់វាថា វាជាចារបុរសរបស់ពូស្មិត តាំងពីយូរយារណាស់មកហើយ ។ គ្រាន់តែជ្រូកនិយាយចប់ភ្លាមអាឆ្កែស្លុះទៅត្របាក់កជ្រូកទាំងបួនស្លាប់មួយរំពេច ។ អាឈ្មុះស្រែកហៅឱ្យសត្វដទៃទៀត ចេញមកលាតត្រដាងកំហុសរបស់ខ្លួន ។ ភ្លាមនោះទាបីដែលបានបំបះបំបោរមាន់ឱ្យពង់ទំលាក់ពីលើធ្នឹម ដើម្បីកុំឱ្យអាឈ្មុះអាចយកទៅលក់ឯផ្សារបាន បានចេញមកហើយរៀបរាប់ពីកំហុសរបស់ខ្លួន ។ វា



ប្រាប់អង្គប្រជុំថា វាបានយល់សប្ដិឃើញអាសំឡីមកប្រាប់វាឱ្យប្រឆាំងនឹងអាឈ្មុះ ។ និយាយចប់ភ្លាម ទាទាំងបីក៏ត្រូវឆ្កែខាំកប្រល័យជីវិតទៀត ។ បន្ទាប់មកក្ងានមួយដើរចេញមកសារភាពថា វាបានលួចពោតស៊ីកាលពីឆ្នាំទៅមិញ ។ អាពពែមួយទៀតប្រាប់ថា វាបាននោមដាក់ក្នុងអាងទឹកដោយមានការបង្ខិតបង្ខំពីអាសំឡី ។ ពពែពីរទៀតប្រាប់ថាវាបានសម្លាប់ហើយស៊ីចៀមកញ្ចាស់មួយដែលជាសាវ័កយ៉ាងជិតស្និទ្ធរបស់អាឈ្មុះ ។ ពពែពីរនេះនាំគ្នាដេញចៀមកញ្ចាស់ដែលឈឺស្រាប់ឱ្យរត់ជុំវិញគុកភ្លើង ទាល់តែសៀរយកម្លាំងរហូតដល់ដាច់ខ្យល់ស្លាប់ ។

លុះបានចេញមក ថ្លែងកំហុសរបស់ខ្លួនសព្វគ្រប់ហើយ សត្វនីមួយៗត្រូវទោសប្រហារជីវិត នៅមុខសត្វទាំងអស់ ។ ការសារភាពទោស និងការប្រហារជីវិត ក៏បន្តរហូតដល់មានគំនរខ្មោចគរលើគ្នានៅមុខអាឈ្មុះ ។ ខ្យល់ទៅជាមានខ្ពិនឆ្អាបដោយឈាមស្រស់ៗ ។ គ្មានសត្វណាមួយធ្លាប់ឃើញអ្វីយ៉ាងនេះសោះតាំងពីថ្ងៃបដិវត្តន៍មក ។

ការពិឃាតចប់ហើយ ។ សត្វទាំងឡាយ លើកលែងតែជ្រូកនិងឆ្កែ ក៏ដកខ្លួនថយដោយសេចក្ដីភិតភ័យញាប់ញ័ររន្ធត់ និងសេចក្ដីទុក្ខព្រួយ ។ គ្មានពេលណាដែលធ្វើឱ្យរារន្ធត់ចិត្ត

ដូចជាពេលនេះឡើយ ។ តើនេះមកពីសត្វទាំងនោះបានក្បត់ ហើយចូលដៃចូលជើងជាមួយភោសំឡី ។ ឬមួយក៏ជាការសងសឹកយ៉ាងព្រៃផ្សៃរបស់រាណ្ហុះ? កាលពីដើម វាក៏ធ្លាប់ឃើញការសម្លាប់ដែរ តែប៉ុន្តែនេះវាដូចជាខុសពីមុន ព្រោះវាជាការកាប់សម្លាប់គ្នាឯង ។ តាំងពីផ្ទួបដិវត្តន៍មក វាមិនទាន់ដែលឃើញសត្វណាសម្លាប់គ្នាឯងដូច្នេះទេ ។ សូម្បីតែកណ្ដុរតូចមួយក៏ពុំទាន់មានសត្វណាសម្លាប់ចោលទទេៗដែរ! ។ វាទាំងអស់នាំគ្នាដើរតំរង់ទៅលើទួល កន្លែងដែលវាកំពុងសង់រហាត់ខ្យល់ ។ ដល់ហើយវានាំគ្នាដាក់ខ្លួនទំរេតលើស្មៅហាក់ដូចជាសុំសេចក្ដីកក់ក្ដៅពីធម្មជាតិ ។ គេឃើញមីគណ្ដូបសេះ - មីក្លុក - អាភ្លី - មេគោ - ពពែ - ចាន់ - ទា - ស្ទើរតែសត្វទាំងអស់ លើកលែងតែឆ្មាដែលវារត់ពួនបាត់តាំងពីមុនពេលប្រជុំ ។ អាព្រួញឈរស្ងៀមធ្មឹង ។ រួចវាដើរចុះដើរឡើងត្រឺត្រវាត់កន្ទុយ យូរៗបញ្ចេញសម្លេងថ្ងូរដោយឈឺចាប់ ។ ទីបំផុតវាពោលឡើងថា ៖

" អញដូចជាមិនយល់សោះ! អញមិនដែលនឹកនាសោះថាវាអាចមានឧបទ្ទវហេតុយ៉ាងខ្លោចផ្សានេះក្នុងភូមិយើង ។ នេះវាមកពីកំហុសរបស់យើងម្នាក់ៗ ។ ឯមធ្យោបាយសំរាប់ដោះស្រាយ អញដូចជាគ្មានឃើញអ្វីក្រៅពីធ្វើការឲ្យគាន់តែច្រើន



នោះទេ ។ ចាប់ពីថ្ងៃនេះទៅ អញត្រូវក្រោកឲ្យបានមុនគេមុនម៉ោងមួយម៉ោងរាល់ព្រឹក" ។

ការកើយវាដើរទៅរកកន្លែងបំបែកថ្ម ។ វាប្រមូលដុំថ្មតូចៗដាក់ក្នុងរទេះ ហើយអូសយកទៅកន្លែងសំណង់ ។ វាធ្វើការរហូតដល់យប់ ។

សត្វទាំងអស់ ដេកប្រជ្រៀតគ្នានៅជុំវិញមីគណ្ដូបសេះយ៉ាងស្ងៀមស្ងាត់ ។ ពីលើទួលវាឃើញទេសភាពលាតសន្ធឹងដាច់កន្ទុយភ្នែក : វាលស្មៅធំធេងរហូតដល់ផ្លូវធំ វាលចំបើងល្វឹងល្វើយ - ព្រៃគម្ពោត - ស្រះទឹក - វាលស្រែដែលមានពណ៌ខៀវស្រងាត់ - ដំបូលផ្ទះដែលមានផ្សែងហុយខ្ពុលៗទៅលើ ។

ល្ងាចដ៏ត្រជាក់មួយ ស្មៅនិងរលីដែលព័ទ្ធជុំវិញរបងចាំងភ្លឺផ្លេកៗ ដោយត្រូវរស្មីព្រះអាទិត្យពេលអស្ដង្គត ។ ទេសភាពនេះគឺទេសភាពភូមិសម្រែង ។

វានៅតែជឿដោយរំភើបថា នេះជាភូមិរបស់វា ។ កន្លែងណាក៏ដូចជាកន្លែងណា ជាសម្បត្តិរបស់វាទាំងអស់គ្នា សម្បត្តិដែលវាស្រឡាញ់ កន្លែងដែលវាចង់រស់នៅ ។ ឃើញទេសភាពល្អយ៉ាងនេះ មីគណ្ដូបសេះអត់ទ្រាំទប់ទឹកភ្នែកមិនបាន ។ បើវាអាចរៀបរាប់ពីទឹកចិត្តពិតរបស់វាកើត

វានឹងនិយាយប្រាប់គេថា កន្លែងនេះហើយដែលវាទាំងអស់បានព្រួតដៃគ្នារំលំការគ្រប់គ្រងនៃអំណាចផ្តាច់ការ ។ ការកាប់សម្លាប់គ្នា និងទិដ្ឋភាពដ៏រន្ធត់នេះ វាទាំងអស់មិនបាននឹកឃើញសោះឡើយ នៅពេលយប់ដែលអាគំនិតបានបបួលធ្វើបដិវត្តន៍ ។ យប់នោះ វាស្រមៃឃើញសង្គមមួយដែលសត្វទាំងអស់នឹងបានចាកផុតរួចពីសេចក្ដីស្រេកឃ្លាន និងទារុណកម្មនៃមនុស្ស ។ សត្វទាំងអស់នឹងមានសេរីភាពស្មើៗគ្នា ។ ម្នាក់ៗនឹងធ្វើការតាមសមត្ថភាពរៀងៗខ្លួន ។ អ្នកខ្លាំងនឹងការពារអ្នកខ្សោយ - ដូចជាវាបានយកជើងវាការពារហ្វូងកូនទា នៅយប់ដែលអាគំនិតបានធ្វើសន្និសីទនោះឯង ។ វាមិនយល់សោះ - មិនយល់ទាល់តែសោះ ថាតើហេតុអ្វីបានជារហូតមកដល់ពេលនេះ គ្មានសត្វណាមួយហ៊ាននិយាយពីសេចក្ដីពិត ក្នុងពេលដែលទាំងអស់គ្នាឈរមើលឆ្កែស្រេកគ្រហឹមពាសពេញកន្លែង - ឈរមើលសត្វគ្នាឯង ដែលត្រូវស្លាប់ ថ្វីបើគ្នាបានទទួលសារភាពកំហុសរបស់ខ្លួនរួចហើយក៏ដោយ ។ ទាំងអស់នេះមិនមែនប្រឆាំងនឹងគំនិតបដិវត្តន៍អ្វីឡើយ ។ វាយល់ច្បាស់ណាស់ថា សត្វទាំងអស់បានសេចក្ដីសប្បាយច្រើនជាងពីកាលជំនាន់ពូស្មិត ហើយសំខាន់ជាងអ្វីទាំងអស់ ក្នុងពេលនេះ ទាំងអស់គ្នាត្រូវតែរួមសាមគ្គីដើម្បី



ប្រឆាំងកុំឲ្យពូស្មិត ត្រឡប់មកវិញកើត ។ អ្វីៗដែលផុតទៅហើយត្រូវបំភ្លេចចោល ។ សត្វទាំងអស់ត្រូវមានសេចក្ដីស្មោះស្ម័គ្រនឹងគំនិតបដិវត្តន៍តទៅទៀត - ត្រូវខំធ្វើការឲ្យកាន់តែច្រើនឡើង នឹងយកបញ្ជាពីលើទៅអនុវត្ត ព្រមទាំងទទួលស្គាល់ អាឈ្មុះជាមេដឹកនាំ ។

ក៏ប៉ុន្តែ វាមានចិត្តមួយនៅស្អាក់ស្ទើរ ។ មិនមានដើម្បីតែអាឈ្មុះមួយទេ ដែលវានៅមានសេចក្ដីសង្ឃឹមនឹងធ្វើការតទៅទៀត នឹងខំសង់រហាត់ខ្យល់ឲ្យបានសំរេច ហើយនឹងយកខ្លួនរងគ្រាប់កាំភ្លើងរបស់មនុស្ស ។ នេះហើយជាគំនិតរបស់មីកណ្ដូបសេះ ដែលវាមិនអាចនឹងរៀបរាប់ជាសំដីឲ្យបានក្បោះក្បាយកើត ។

ទីបំផុត ដោយមានការតានតឹងក្នុងចិត្តពេក ដោយរកពាក្យនិយាយមិនចេញ វាក៏ចាប់ច្រៀងចម្រៀងបដិវត្តន៍ ។ ឮដូច្នោះហើយ សត្វទាំងអស់ក៏នាំគ្នាច្រៀងតាម ។ វានាំគ្នាច្រៀងបីដង - ច្រៀងដោយស្រៀបក្រំនិងក្ដុកក្ដួលក្នុងចិត្តបំផុត ។ វានាំគ្នាច្រៀងយ៉ាងស្រងូតស្រងាត់ ។ វាពុំដែលបានច្រៀងយ៉ាងនេះឡើយពីមុនមក ។

គ្រាន់តែច្រៀងចប់ភ្លាម គេឃើញអាប្រាជ្ញដើរចូលមក ព្រមទាំងមានឆ្កែពីរមកជាមួយផង ។ វាមានទឹកមុខបង្ហាញ

ថាមានរឿងសំខាន់អ្វីមួយនឹងប្រាប់ ។ ដល់ហើយវាប្រកាសថា ចាប់ពីថ្ងៃនេះតទៅ ដោយមានច្បាប់ពិសេសចេញពីអាណ្ណុះ ចំរៀងបដិវត្តន៍ត្រូវលុបចោល ហើយហាមផ្តាច់មិនឱ្យនរណាច្រៀងបទនេះតទៅទៀតឡើយ ។

សត្វទាំងឡាយកាន់តែមានការងឿងឆ្ងល់ ។

“ម៉េចបានជាមិនឱ្យយើងច្រៀង?” មីភ្លុកស្រែកសួរទទឹង :

“ព្រោះគេឈប់ត្រូវការ” អាប្រាំជូឆ្លើយភ្លាម “ចម្រៀងបដិវត្តន៍គឺគេត្រូវច្រៀងពេលមានបដិវត្តន៍ ។ ឥឡូវបដិវត្តន៍ចប់សព្វគ្រប់ហើយចម្រៀងនេះក៏ត្រូវតែចោល ។ ការប្រហារជីវិតនៃជនក្បត់ជាតិល្ងាចមិញនេះ ជាការបង្ហើយនៃបដិវត្តន៍របស់យើង ។ ឥឡូវសត្រូវទាំងក្នុងទាំងក្រៅបានចុះចាញ់អស់ហើយ ។ ក្នុងចំរៀងបដិវត្តន៍ យើងបានសម្តែងសេចក្តីសង្ឃឹមនឹងសាងសង្គមមួយថ្មី - ឥឡូវសង្គមនោះ បានកើតឡើងហើយ ដូច្នេះចំរៀងបដិវត្តន៍ឃើញថាគ្មានប្រយោជន៍អ្វីទៀតទេ” ។ សត្វទាំងអស់ស្តាប់ដោយក្តីភិតភ័យនិងព្រួយបារម្ភ ។ វាចង់សួរហេតុផលទៀត តែក្នុងពេលនោះ ពួកពពែក៏ចាប់ស្រែកពាក្យស្លោក “ជើងបួនល្អ-ជើងពីរអាក្រក់” ឮលាន់រំពងឡើងធ្វើឱ្យការជជែកត្រូវបញ្ចប់ភ្លាម ។



ចាប់ពីពេលនោះមកគេលែងឮចម្រៀង“បដិវត្តន៍” ទៀតហើយ ។ ដើម្បីជារបស់ជំនួសអា “គី” ដែលជាជ្រូកធ្លាប់ល្បីឈ្មោះខាងតែងកំណាព្យ ក៏បានតែងកំណាព្យមួយដែលចាប់ផ្តើមថា ៖

“សត្វភូមិសម្រែង
ចូរឯងចាំទុក
ថ្ងៃនេះថ្ងៃមុខ
បានសុខគ្រប់គ្នា . . .”

នេះគឺជាចំរៀងថ្មី ដែលសត្វទាំងអស់ច្រៀងរាល់ព្រឹកថ្ងៃអាទិត្យក្រោយពីបានបង្ហូតទង់រួច ។ ក៏ប៉ុន្តែសំដីនិងទំនុកនៃចំរៀងថ្មីនេះ ពុំបានធ្វើឱ្យសត្វទាំងឡាយភ្ញាក់ស្មារតីដូចជាចំរៀង “បដិវត្តន៍” ដែលវាបានធ្លាប់ច្រៀងតាំងពីដើមមកឡើយ ។

## ចំពូក ៨

បីបួនថ្ងៃកន្លងផុតទៅ សេចក្ដីតក់ស្លុតនិងក្រៀមក្រំនៃសត្វទាំងឡាយក៏បានអន់ស្បើយបន្តិចម្ដងៗ ។ សត្វខ្លះនៅចាំបានយ៉ាងច្បាស់ថា មាត្រាប្រាំមួយនៃធម្មនុញ្ញ បានចែងថា ៖ "សត្វមិនត្រូវសម្លាប់សត្វគ្នាឯង" ។ តែគ្មាននរណាមួយហ៊ានជំទាស់ នៅពេលដែលគេយកជ្រូកទៅប្រហារជីវិតទេ ព្រោះមានខ្លះជឿថា មាត្រាប្រាំមួយនេះគ្មានទាក់ទងនឹងការប្រហារជីវិតនេះឡើយ ។

មីកណ្ដុបសេះអង្វរឱ្យអាភ្លើ អានមាត្រានេះឱ្យវាស្ដាប់ ។ អាភ្លើប្រកែកមិនព្រមអាន ដោយសំអាងថា ខ្លួនវាមិនចង់ច្របូកច្របល់ក្នុងរឿងនេះទេ ។ មីកណ្ដុបសេះក៏រត់ទៅរក "មីភ្លុក" ។ មី "ភ្លុក" អានឱ្យមីកណ្ដុបសេះស្ដាប់ ៖ មាត្រាប្រាំមួយចែងថា ៖ "សត្វមិនត្រូវសម្លាប់សត្វគ្នាឯងដោយឥតហេតុផល" ។ ពាក្យប៉ុន្មានម៉ាត់ក្រោយនេះដូចជាពុំដែលឮសោះ ។ បើដូច្នោះមែន ការប្រហារជីវិតនេះដូចជាមិនខុសពីមាត្រានៃធម្មនុញ្ញឡើយ ព្រោះការប្រហារជីវិតនេះត្រូវធ្វើ



ឡើងចំពោះសត្វណាដែលបានក្បត់ ចូលដៃជាមួយខ្មាំង គឺអាសំឡី ។

នៅឆ្នាំនេះ សត្វទាំងអស់ធ្វើការកាន់តែច្រើនជាងឆ្នាំទៅ ។ វាត្រូវសង់ជញ្ជាំងរហាត់ខ្យល់ ដែលក្រាស់ជាងមុនពីដង ហើយត្រូវសង់ឱ្យហើយទាន់ពេលដែលបានកំណត់ទុក ព្រមទាំងត្រូវបំពេញកិច្ចការទាំងឡាយក្នុងស្រែ - ចំការទៀតផង ។ ពេលនេះហើយដែលសត្វទាំងអស់ដឹងខ្លួនថា វាបានធ្វើការច្រើន តែបានចំណីតិចតួចស្ដួចស្ដើងជាងជំនាន់មុនបដិវត្តន៍ ។

នៅព្រឹកថ្ងៃអាទិត្យ អាប្រាជ្ញចេញមក ទាញក្រដាសយ៉ាងវែងមកអានឱ្យអង្គប្រជុំស្ដាប់ថា "ផលិតផលនៃដំណាំផ្សេងៗ បានកើន ២០០ ភាគរយ ខ្លះបាន ៣០០ ភាគរយ ខ្លះទៀតបាន ៥០០ ភាគរយ" ។ សត្វទាំងឡាយ លុះបានស្ដាប់ហើយ ក៏នាំគ្នាជឿទាំងអស់ ព្រោះវាភ្លេចអស់ហើយពីការរស់នៅមុនថ្ងៃបដិវត្តន៍ ហើយវានៅសង្ឃឹមក្នុងចិត្តថាថ្ងៃណាមួយវានឹងបានចំណីកាន់តែច្រើន ទោះផលិតផលចុះឬឡើងក៏ដោយ ។

ឥឡូវបញ្ជាទាំងឡាយត្រូវធ្លាក់មកតាមរយៈអាប្រាជ្ញ ឬក៏តាមចំណោមជ្រូកណាមួយ ។ អាឈ្មុះ ឥឡូវមិនសូវចេញ

មុខមកក្រៅដូចពីមុនឡើយ ។ បើវាចេញមកក្រៅម្ដងៗតែងតែមានហ្វូងឆ្កែដើរអមជាមួយ និងមានមាន់ខ្មៅមួយដើរពីមុខហាក់ដូចជាអ្នកផ្លុំត្រែ ។ អាមាន់នេះត្រូវរងាវមួយសិន មុននឹងអាឈ្មុះចាប់ផ្ដើមនិយាយ ។ ក្នុងក្រោល អាឈ្មុះមានកន្លែងផ្សេងពិសេសដាច់ពីសត្វដទៃទៀត ។ វាស៊ីម្នាក់ឯង ហើយចំណីវាត្រូវដាក់ចាន ឬថាសដែលវាយកចេញពីក្នុងផ្ទះពូស្មិត ព្រមទាំងមានឆ្កែពីរអង្គុយយាមជានិច្ចផង ។ ចាប់ពីថ្ងៃនេះទៅ កាំភ្លើងត្រូវបាញ់បីដងក្នុងមួយឆ្នាំ គឺក្នុងថ្ងៃរំលឹកបដិវត្តន៍ម្ដង ថ្ងៃរំលឹក "ប្រតិបត្តិការសឹកសម្រែងជ័យ" ម្ដង និងថ្ងៃរំលឹកកំណើតអាឈ្មុះម្ដង ។

ឥឡូវសត្វទាំងឡាយឈប់ហៅអាឈ្មុះចំឈ្មោះហើយ ។ វាហៅថា "រៀមច្បងបដិវត្តន៍" ឬក៏ "មេដឹកនាំយើង !" ។ ពួកជ្រូកបានបង្កើតងារថ្មីៗ សំរាប់វាដូចជា៖ "បិតានៃសត្វទាំងពួង" - "មេបដិវត្តន៍" - "បិតារក្សាពូជសត្វ" - "មិត្តនៃសត្វទាំងពួង" ។ល។

រាល់ផង អាប្រាដូតែងដំណាលពីគតិបណ្ឌិតនៃអាឈ្មុះ ។ វានិយាយបណ្ដើរ យំបណ្ដើរយ៉ាងក្ដុកក្ដួល ។ វាដំណាលពីសន្ដានចិត្តដ៏សប្បុរសនិងពីសេចក្ដីមេត្តាករុណារបស់អាឈ្មុះដល់សត្វទាំងអស់ក្នុងពិភពលោក ជាពិសេសដល់សត្វទាំង



ឡាយណាដែលកំពុងរស់នៅក្នុងសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីវេទនា ។ ឥឡូវសត្វទាំងអស់ថ្លែងមិនដាច់ពីមាត់នូវសមិទ្ធិទាំងឡាយដែលសុទ្ធតែជាស្នាដៃរបស់អាឈ្មុះ ។ គេសង្កេតឃើញមេមាន់មួយតែងនិយាយថា៖ "ក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃរៀមច្បងបដិវត្តន៍របស់យើង អញពងបាន ៥ ក្នុងរយៈពេលតែ ៦ ថ្ងៃ" ជួនកាលគេឮមេគោដែលកំពុងផឹកទឹកក្នុងស្រះ ឧទានឡើងថា៖ "សូមរៀមច្បងបដិវត្តន៍ ចូរចំរើន - ទឹកស្រះនេះមានឱជារសឆ្ងាញ់អ្វីម្ល៉េះទេ !" ដើម្បីសំដែងនូវទឹកចិត្តស្មោះត្រង់ចំពោះមេដឹកនាំថ្មីនេះ អា "គរី" បានសរសេរកំណាព្យមួយ ដែលមានចំណងជើងថា៖ រៀមច្បងបដិវត្តន៍ :

រៀមច្បងបដិវត្តន៍ ជាប្រភព
នៃសុភមង្គល ។
រៀមច្បងបិតា នៃសត្វកំព្រា
ជួបភក្ត្ររាល់គ្រា ជាទីកក់ក្ដៅ
នៃសត្វទាំងពួង ។
រៀមច្បងបដិវត្តន៍ ជាប្រភព
នៃសន្តិភាព ។
ចំណីចំណុក មានគ្រប់មានសព្វ

សម្បូណ៌-សប្បាយ　គ្រប់កាយបានសុខ
អស់ទុកទាំងពួង ។
រៀមច្បងបដិវត្តន៍　ជាប្រភព
នៃយុត្តិធម៌ ។
ពីថ្ងៃនេះទៅ　ត្រូវប្រៀនប្រដៅ
សត្វតូចសត្វធំ　ចេះលូនចេះក្រាប
ចេះថ្វាយបង្គំ　គុណមេដឹកនាំ
គុណរកផ្ទឹមគ្មាន ។

អាឈ្មុះពេញចិត្តនឹងកំណាព្យនេះណាស់ ហើយបញ្ជាឲ្យគេសរសេរដាក់លើផ្ទាំងជញ្ជាំងជង្រុក ទន្ទឹមគ្នានឹងធម្មនុញ្ញ ។ មានរូបអាឈ្មុះ ដែលអាប្រាជ្ញគូរនឹងពណ៌ស ព្យួរដាក់ក្បែរនឹងកំណាព្យនេះផង ។

តាមរយៈពូពាង អាឈ្មុះបានធ្វើការទាក់ទងជាមួយពូយៀង និងពូថង ។ ឈើហ៊ុបនៅមិនទាន់បានលក់ឲ្យនរណាទេ ។ ពូយៀងចង់បានឈើហ៊ុបនេះណាស់ តែគាត់ឲ្យថ្លៃថោកពេក ។ ម្យ៉ាងទៀត ក្នុងពេលថ្មីៗនេះ មានពាក្យចចាមអារាមថា ពូយៀងនិងគ្នីគ្នាគាត់មានគំរោងការនឹងមកវាយដណ្ដើមយកភូមិសម្រែង ព្រមទាំងបំផ្លាញរហាត់ខ្យល់ផង ព្រោះរហាត់ខ្យល់នេះបានធ្វើឲ្យគាត់មានសេចក្ដីច្រណែន



និន្ទានិងក្ដៅក្រហាយ ។

មានពាក្យលេចឮមកថា អាសំឡីនៅពួនក្នុងភូមិត្រពាំងស្រកីដដែល ។ កាលពីខែមុន សត្វទាំងឡាយបានភ្ញាក់ផ្អើល ដោយបានដឹងថា មានមេមាន់បីបានចូលដៃជាមួយអាសំឡីបំរុងនឹងធ្វើឃាតកម្មដោយដាក់ថ្នាំបំពុលលើរូបអាឈ្មុះ។ មេមាន់ទាំងនោះត្រូវគេយកទៅសម្លាប់ចោលភ្លាមហើយចាប់ពីពេលនោះមក ការប្រុងប្រយ័ត្នដើម្បីសន្តិសុខរបស់អាឈ្មុះក៏ចាប់ផ្ដើមសកម្មភាព ។

រាល់យប់មានឆ្កែយាមកន្លែងវាដេកនៅគ្រប់ជ្រុង ហើយមានកូនជ្រូកមួយឈ្មោះអា "ភ្លក់" ជាអ្នកចាំភ្លក្សចំណីរបស់វាមុន ក្រែងលោមាននរណាមាន បំណងលួចដាក់ថ្នាំបំពុល ។ ឥឡូវមានដំណឹងមកថាអាឈ្មុះបានសុខចិត្តលក់ឈើហ៊ុបឲ្យពូថងហើយ ហើយវាបានអនុញ្ញាតឲ្យពូថងចេញចូលភូមិសម្រែងបានតាមចិត្ត ក្នុងការទិញដូរផលិតផលផ្សេងៗ ។ ការទាក់ទងរវាងអាឈ្មុះនិងពូថង កាលពីដើមមានតែតាមរយៈពូពាងទេ ឥឡូវការទាក់ទងនេះកាន់តែមានការស្និទ្ធស្នាលឡើង ។ សត្វក្នុងភូមិសម្រែងស្អប់ពូថងណាស់ តែទោះជាយ៉ាងណាក៏ដោយក៏វានៅចូលចិត្តពូថងជាងពូយៀង ដែលវាស្អប់ហើយខ្លាចទៀតនោះ ។ រឿង

ប្រាំងជិតផុតទៅទៀតហើយ សំណង់រហាត់ខ្យល់ក៏ជិតបាន សំរេច ។ ដំណឹងថា នឹងមានគំរោងការក្បត់ក៏កាន់តែច្បាស់ឡើង ៗ ។ ពាក្យចចាមអារាមលេចឮមកថា ពួកយៀង និងគ្នាគាត់ប្រហែលម្ភៃនាក់ ប្រដាប់ដោយអាវុធ នឹងចូលមកលុកលុយភូមិសប្រែង ។ ដំណឹងដដែលបានផ្សាយថា គាត់បានទៅឃុបឃិតជាមួយមេឃុំ និងប៉ូលីស រួចជាស្រេចហើយ ។ បើគាត់វាយដណ្ដើមភូមិនេះបាន គាត់នឹងមកនៅ ហើយយកភូមិនេះជាសម្បត្តិរបស់គាត់ដោយគ្មានឱ្យនរណាតវ៉ាបានទេ ។ ដំណឹងមួយទៀតលេចឡើងថា ពួកយៀងបានធ្វើទារុណកម្មផ្សេង ៗ លើសត្វទាំងឡាយក្នុងភូមិត្រពាំងស្រកី ដែលជាភូមិរបស់គាត់ ៖ គាត់បានសំពងសេះមួយទាល់តែស្លាប់ - បង្អត់ចំណីគោ - សម្លាប់ឆ្កែដោយបោះវាចូលទៅក្នុងភ្នក់ភ្លើង - ហើយចាប់មាន់ឱ្យជល់គ្នាដោយយកកាំបិតយ៉ាងមុតចងជាប់នឹងខ្នាយ ។ សត្វទាំងអស់មានសេចក្ដីក្ដៅក្រហាយណាស់ កាលណាឮទារុណកម្មដ៏សាហាវយង់ឃ្នង ដែលសត្វជាសម្លាញ់របស់វាត្រូវរងគ្រោះយ៉ាងនេះ ។ វាទាំងអស់អន្ទះអន្ទែងក្នុងចិត្តចង់ទៅវាយកំទេចភូមិត្រពាំងស្រកី ហើយបណ្ដេញពួកយៀងដើម្បីរំដោះសត្វទាំងអស់ឱ្យបានផុតពីសេចក្ដីរងកម្ម ។ ក៏ប៉ុន្តែអាប្រាជ្ញ



បានទំពក្យរបស់សត្វទាំងអស់ថា កុំធ្វើអ្វីតាមកំហឹងពេក ហើយសុំឱ្យជឿលើផែនការរបស់អាឈ្មុះវិញ ។

កំហឹងនឹងពួកយៀងបានកាន់តែខ្លាំងឡើង ៗ ។ នៅពេលប្រជុំព្រឹកថ្ងៃអាទិត្យ អាឈ្មុះចេញមកហើយអធិប្បាយប្រាប់សត្វទាំងអស់ថា តាំងពីដើមមក វាមិនដែលមានគំនិតចង់ទាក់ទងជាមួយពួកយៀងទេ ។ ចំណែកឈើហ៊ុបនោះ ក៏វានឹងមិនលក់ឱ្យពួកយៀងដែរ ព្រោះការទាក់ទងជាមួយមនុស្សរបៀបពួកយៀងធ្វើឱ្យអាប់កិត្តិយសដល់វា និងដល់ភូមិសប្រែង ។

ហ្វូងព្រាបដែលបានបញ្ជូនឱ្យទៅឃោសនាពីគំនិតបដិវត្តន៍ ឥឡូវត្រូវហាមមិនឱ្យចូលទៅក្នុងភូមិទួលក្រាំងសៀមទៀតឡើយ ។ ហើយពាក្យស្លោកពីមុនដែលថា “ បរាជ័យមនុស្សជាតិ” ឥឡូវគេបកជា “បរាជ័យពួកយៀង” វិញ ។ មានរឿងសំខាន់មួយទៀត ដែលគេថាជាឧបាយកលរបស់អាសំឡី ក៏ត្រូវបានលាតត្រដាងនៅមុខអង្គប្រជុំ ។ អាឈ្មុះថាអាសំឡីបានលួចស្រូវហើយយកស្មៅមកដាក់បំពេញវិញ ហើយនៅល្ងាចមួយនោះ វាបានយកគ្រាប់ស្មៅមកចាក់លាយជាមួយគ្រាប់ពោត ។ រឿងទាំងនេះ ជារឿងពិត ព្រោះអាក្ងានមួយនោះបានមកសារភាពទោសនៅចំពោះមុខអាប្រាជ្ញថា

វាបានចូលដៃជាមួយអាសំឡី ក្នុងរឿងការនេះដែរ ។ បន្តិចក្រោយមក អាគ្វាននោះ ក៏លេបថ្នាំពុលសម្លាប់ខ្លួនឯងបាត់ទៅ ។ វាថាសត្វទាំងអស់ត្រូវឈប់ជឿថាអាសំឡីបានមេដាយ "វីរៈបុរសថ្នាក់ទី១" ព្រោះរឿងនេះត្រូវបានប្រឌិតឡើងដោយអាសំឡីខ្លួនឯង ក្រោយពី "ប្រតិបត្តិការសម្រែងជ័យ" ។ មិនត្រឹមតែពុំបានទទួលឥស្សរិយយសនេះទេ អាសំឡីត្រូវគេផ្តន្ទាទោសទៀត ដោយវាពុំបានបញ្ចេញសេចក្តីក្លាហាននៅពេលប្រយុទ្ធ ។ ជាថ្មីម្តងទៀត សត្វទាំងអស់ស្តាប់ពាក្យនេះដោយសេចក្តីងឿងឆ្ងល់ តែអាប្រាជ្ញនៅតែខំពន្យល់បន្ថែមថា នេះមកតែពីសត្វអស់នោះគ្មានប្រាជ្ញា ម៉្លោះហើយការចាំក៏ពុំសូវមានដែរ ។

នៅខែនេះ សត្វទាំងអស់ត្រូវប្រឹងធ្វើការស្ទើរហួសកម្លាំង ព្រោះការច្រូតកាត់ត្រូវបង្ហើយព្រមគ្នាជាមួយនឹងរហាត់ខ្យល់។ គ្រឿងចក្រនៅមិនទាន់បានរៀបចំដាក់នៅឡើយទេ ថ្វីបើជញ្ជាំងត្រូវបានធ្វើរួចស្រេចហើយក៏ដោយ ។ ពូពាងសន្យាថា នឹងដើរទិញគ្រឿងចក្រនិងសម្ភារៈផ្សេងៗឲ្យ ។ ទោះបើមានឧបសគ្គ - កង្វះការពិសោធន៍ - ធ្វើការមិនត្រូវតាមវិធីសាស្ត្រ និងអំពើព្យាបាទពីអាសំឡីក៏ដោយ ក៏គំរោងការរហាត់ខ្យល់បានសម្រេចទាន់ពេលវេលាដែរ ។ សត្វទាំង



អស់ដើរជុំវិញរហាត់ខ្យល់ដោយអស់កម្លាំង តែដោយសេចក្តីពេញចិត្តនឹងស្នាដៃឯករបស់វា ។ មើលទៅរហាត់ខ្យល់ថ្មីនេះ វាដូចជាល្អជាងរហាត់ខ្យល់ដែលវាសង់ពីលើកមុន ព្រោះជញ្ជាំងក៏ក្រាស់ហើយមាំ មិនអាចនឹងបំផ្លាញបានដោយងាយៗឡើយ ។

វានឹកឃើញអស់ហើយនូវការនឿយហត់ នូវឧបសគ្គនិងសេចក្តីអស់សង្ឃឹម ។ តែឥឡូវ តើវាសប្បាយចិត្តប៉ុណ្ណាទៅ បើប្រសិនជាវាដឹងថាក្តាងនោះនឹងវិល ឌីណាម៉ូនឹងដើរ ! ។ នឹកដល់រឿងនេះឡើង សេចក្តីនឿយហត់របស់វាទាំងប៉ុន្មានបានបាត់អស់រលីង ។ គេឃើញវារត់ជុំវិញរហាត់ខ្យល់នេះដោយសេចក្តីរីករាយ ព្រមទាំងស្រែកហ៊ោកញ្ជ្រៀវដោយជ័យជំនះ ។

អាឈ្មុះដើរមកត្រួតរហាត់ខ្យល់ ដោយមានឆ្កែដើរអមជាមួយនិងមាន់ខ្មៅដើរពីមុខ ។ វាថ្លែងសេចក្តីសរសើរដល់សត្វទាំងអស់ដែលបានបំពេញកិច្ចការនេះ ហើយប្រកាសប្រាប់សត្វទាំងអស់ថា វានឹងដាក់ឈ្មោះរហាត់ខ្យល់នេះថា "រហាត់បិតាប្រទានភ្លើង" ។ ពីរថ្ងៃក្រោយមកសត្វទាំងអស់ត្រូវចូលមកប្រជុំពិសេសមួយនៅក្នុងជង្រុក ។ វាភ្ញាក់ខ្លួនព្រើត កាលបានឮអាឈ្មុះប្រកាសថា វាបានលក់ឈើហុបឱ្យពូយៀង

ហើយ ។ ស្រុកនេះពូយៀងនឹងមកករកេះបកសឹកកើតទៀតពីភូមិ ។ គ្មាននរណាចាយព្រួយសោះ ព្រោះក្នុងពេលដែលវាធ្វើជាត្រូវរ៉ូវជាមួយពូថង អាណ្ហុះក៏បានធ្វើការទាក់ទងដោយលួចលាក់ជាមួយពូយៀងដែរ ។

ដូច្នេះការទាក់ទងរកស៊ីជាមួយភូមិ "ទួលព្រាំងសៀម" ត្រូវបញ្ចប់ និងដាច់ចំណងតែម្តង ។

ពាក្យពេចន៍អាក្រក់និងបណ្តាសាបានឮទៅដល់ពូថង ។ សត្វព្រាប បានទទួលបញ្ជាមិនឲ្យទៅឃោសនា នៅភូមិត្រពាំងស្រកីទៀតទេ ហើយពាក្យស្លោកត្រូវកែប្រែទៀតគឺកែពី "បរាជ័យពូយៀង" មក "បរាជ័យពូថង" វិញម្តង ។

អាណ្ហុះបានធានាអះអាងថា ដំណឹងដែលថាមានគេមកវាយដណ្តើមយកភូមិសម្រែងនោះ មិនមែនជាការពិតឡើយ។ ម្យ៉ាងទៀតរឿងទារុណកម្មផ្សេង ៗ ដែលពូយៀងធ្វើទៅលើសត្វក្នុងភូមិគាត់ ក៏ជារឿងប្រឌិតឡើងដែរ ។

ពាក្យនេះសុទ្ធតែពាក្យចចាមអារាម ដែលត្រូវបានប្រឌិតឡើងដោយអាសំឡី និងដៃជើងរបស់វា ។ ឥឡូវដំណឹងពិតលេចឡើងថា អាសំឡីពុំបានពួននៅភូមិត្រពាំងស្រកីទេ ។

តែតាមពិត វាពុំដែលរស់នៅក្នុងភូមិនេះម្តងណាឡើយ ។



វាបានរស់នៅយ៉ាងសប្បាយប៉ុណ្ណោះ នៅភូមិទួលព្រាំងសៀម ក្រោមការថែទាំរបស់ពូថង តាំងពីយូរយារណាស់មកហើយ រហូតមកដល់សព្វថ្ងៃនេះ ។

ជ្រូកទាំងអស់ បានសេចក្តីកោតសរសើរដល់កលល្បិចរបស់អាណ្ហុះ ។ វាធ្វើជាត្រូវជាមួយពូថង ដើម្បីបង្ខំឲ្យពូយៀងទិញឈើថ្លៃមួយជាពីរ ។ ក៏ប៉ុន្តែគុណសម្បត្តិរបស់អាណ្ហុះ មិនមែននៅតែត្រឹមណោះទេ ។ ប្រាជ្ញាវៀងវៃរបស់វា គឺនៅត្រង់ដែលវាមិនដែលជឿលើនរណាទាំងអស់ សូម្បីតែលើពូយៀងក៏ដោយ ។ នេះជាពាក្យពន្យល់របស់អា "ប្រាជ្ញ" ។ ពូយៀងគាត់ចង់ទិញឈើហ៊ុបនោះដោយប្រើឆែក គឺជាក្រដាសមួយសន្លឹកដែលសរសេរឡើងជាពាក្យសន្យា ។ តែអាណ្ហុះឆ្លាតណាស់ វាមិនព្រមទទួលទេ វាសុខចិត្តទទួលយកក្រដាសប្រាក់សុទ្ធដែលវាទារយកពីពូយៀងមុននឹងវាប្រគល់ឈើហ៊ុបឲ្យ ។ ឥឡូវពូយៀងឲ្យលុយសព្វគ្រប់ហើយ ។ គឺលុយនេះឯងដែលអាណ្ហុះនឹងយកទៅទិញម៉ាស៊ីនរហាត់ខ្យល់ ។

ពូយៀងបានដឹកយកឈើហ៊ុបចេញទៅអស់ហើយ ។ អាណ្ហុះបានហៅប្រជុំពិសេសមួយទៀតក្នុងជង្រុក ដើម្បីពិនិត្យលើចំនួនប្រាក់ ដែលបានមកពីការលក់ឈើហ៊ុបឲ្យពូ

ហៀង ។ អាឈ្មុះដែលមានលំអដោយមេដាយបានដាក់ខ្លួនចំរេតលើវេទិកាក្រោលដោយចំហើង ។ វាញញឹមដោយសេចក្តីរីករាយ ។ នៅកៀនជើងវាគឺកញ្ចប់ប្រាក់ដែលដាក់លើចានមួយយ៉ាងស្អាត ។

សត្វទាំងអស់ដើរមកកាន់មុខវេទិកា សំឡឹងមើលអាឈ្មុះដោយគោរព ។ អាព្រួញដើរមកដល់ហើយ ក៏ដាក់ច្រមុះហិតកញ្ចប់ប្រាក់ធ្វើឲ្យក្រដាស់ស្តើង ៗ ពណ៌សប៉ើង ហើយរត់ចូលរន្ធច្រមុះវា ។

បីថ្ងៃក្រោយមក មានការចលាចលមួយកើតឡើង ។ ពូពាង ដោយមានទឹកមុខស្លេកស្លាំង ជិះកង់យ៉ាងលឿនពលមកក្នុងភូមិ ។ ដល់ហើយ គាត់រុញកង់ចោលក្នុងទីធ្លា ហើយក៏រត់យ៉ាងលឿនចូលមកក្នុងជង្រុក ។ មួយរំពេចនោះ គេឮសម្រែកកំហឹងយ៉ាងខ្លាំងចេញពីគ្រែអាឈ្មុះ ។ ដំណឹងបានផ្សាយទៅគ្រប់សត្វក្នុងភូមិ រហ័សដូចជាភ្លើងឆេះព្រៃ ។ គឺថាក្រដាស់ប្រាក់ដែលពូយៀងឲ្យមកអាឈ្មុះ ជាក្រដាស់ក្លែងក្លាយ ! ដូច្នេះពូយៀងបានឈើហ៊ុបទទេ !

អាឈ្មុះហៅសត្វទាំងអស់មកប្រជុំភ្លាម ។ ពោរពេញដោយកំហឹង វាបានប្រកាសកាត់ទោសប្រហារជីវិតលើរូបពូយៀង ។ " កាលណាយើងចាប់វាបាន — វាស្រែក



ឡើង ...“ អាយៀងត្រូវតែគេដាក់ស្ងោរទាំងរស់ ” ។ វាក៏បញ្ជាឲ្យសត្វទាំងអស់ប្រុងប្រយ័ត្នខ្លួន ព្រោះបន្ទាប់ពីការបន្លំនេះមុខជានឹងមានរឿងមិនស្រួលកើតឡើង ។ ពូយៀងនឹងគូកនអាចនឹងមកបំផ្លាញភូមិសម្រែងបានគ្រប់ពេលវេលា ។ ដូច្នេះត្រូវមានការយាមល្បាតគ្រប់កន្លែងចេញចូល ។

ក្នុងពេលដដែល អាឈ្មុះបញ្ជូនសត្វព្រាប ៤ ឲ្យទៅកាន់ភូមិទួលក្រាំងសៀម ដើម្បីនាំសារជាមិត្តភាពក្នុងគោលបំណងនឹងរឹតចំណងឡើងវិញជាមួយពូថង ។

ព្រឹកឡើង ការវាយលុកក៏មានមែន ។ ក្នុងពេលកំពុងបាយព្រឹក ស្រាប់តែសត្វយាមរត់មកប្រាប់ថា ពូយៀងនិងគូកនបានចូលមកជិតដល់ទ្វាររបងភូមិហើយ ។ ដោយសេចក្តីក្លាហាន សត្វទាំងអស់រត់ព្រូព្រមគ្នាតំរង់ទៅទ្វាររបង ។ មើលទៅ វាហាក់ដូចជាពុំបានជ័យជំនះដោយស្រួល ដូចកាលប្រយុទ្ធពីលើកមុនឡើយ ។ មនុស្សទាំងអស់មាន ១៥ នាក់ ប្រដាប់ដោយអាវុធប្រហែលពាក់កណ្តាល ។ គេចាប់បាញ់ភ្លាមនៅពេលដែលគេចូលមកដល់ប្រហែល ៥០ ម៉ែត្រពីរបង ។ សត្វទាំងអស់មិនអាចទ្រាំនឹងស្នូរកាំភ្លើងនេះបានទេ ។ ថ្វីបើអាឈ្មុះនិងអាព្រួញខិតខំប្រមែប្រមូលវាយ៉ាងណាក៏ដោយក៏សត្វទាំងអស់ត្រូវរត់

ថយក្រោយបកវិញ ។ សត្វខ្លះត្រូវរបួសរត់ចូលទៅពួនក្នុងជង្រុកហើយដើបក្បាលតាមប្រហោងជញ្ជាំង ។ ឥឡូវវាលស្មៅ ព្រមទាំងរហាត់ខ្យល់ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃសត្រូវហើយ ។ អាឈ្មុះហាក់ដូចជាចុះចាញ់ ។ វាដើរចុះដើរឡើងដោយឥតចេញស្ដី កន្ទុយត្រង់ត្រវាត់ម្ដង ៗ ។ វានឹកដល់ពូថង ហើយវាសង្ឃឹមថា បើគាត់និងគូកនគាត់មកជួយទាន់ ប្រហែលជាមានសង្ឃឹមមកវិញខ្លះ ។ ក្នុងពេលនោះស្រាប់តែព្រាបទាំងបួន ដែលវាបានបញ្ជូនទៅក្រៅពីប៉ុលមិញ ហើរចូលមក ។ អាមួយនោះមានពាំក្រដាសតូចមួយដែលជាសំបុត្រពីពូថង ។ ក្នុងក្រដាសនោះ មានសរសេរថា : "យើងមកជួយភ្លាម" ។

ពូឃៀងនិងគូកនឈប់នៅត្រឹមរហាត់ខ្យល់ ។ សត្វទាំងអស់ឈរមើលដោយអស់សង្ឃឹម ។ វាឃើញមនុស្សពីរនាក់ដែលប្រដាប់ដោយដំបងដែកនិងពូថៅ ប្រុងនឹងវាយកំទេចរហាត់ខ្យល់ ។

"ទៅមិនរួចទេ! — អាឈ្មុះស្រែកឡើង — យើងបានរៀបជញ្ជាំងក្រាស់ណាស់ ។ វាមិនអាចរំលំរហាត់ខ្យល់យើងបានក្នុងមួយអាទិត្យទេ ចូរសម្លាញ់ទាំងអស់កុំអស់សង្ឃឹម" ។

អាភ្លើនៅតែឈរមើលទៅរហាត់ខ្យល់ដោយយកចិត្តទុក



ដាក់ ។ វាឃើញមនុស្សពីរនាក់កំពុងជីករន្ធនៅក្រោមជញ្ជាំង ។ ឃើញដូច្នោះហើយ វាគក់ក្បាលហាក់ដូចជាយល់ច្បាស់ក្នុងចិត្ត ព្រមទាំងពោលថា :

"អញថាហើយ — វាឧទានឡើង — តើឯងទាំងអស់គ្នាឃើញពួកវាធ្វើអ្វីទេ ? បន្តិចទៀត វានឹងយករំសេវមកញាត់ក្នុងរន្ធនោះ" ។ ដោយសេចក្ដីភិតភ័យ សត្វទាំងអស់ឈរនៅស្ងៀម ។ វាមិនដឹងថានឹងរត់រកកន្លែងជ្រកត្រង់ណាទេ ។ ប៉ុន្មាននាទីក្រោយមក ស្រាប់តែគេឃើញមនុស្សរត់ប្រវាត់ប្រវែងគ្រប់ទិសទី ។ បន្ទាប់មកស្រាប់តែឮសូរផ្ទុះយ៉ាងខ្លាំង ។ សត្វព្រាបហោះព្រាតទៅលើអាកាស ។ លើកលែងតែអាឈ្មុះចេញ សត្វទាំងអស់ព្រាសខ្លួនក្រាបលើដីនិងយកដៃបិទមុខ ។ ដល់វាក្រោកឡើងវិញវាឃើញផ្សែងខ្មៅហុយឃ្លុំនៅកន្លែងរហាត់ខ្យល់ ។ បន្តិចមក ខ្យល់បានផាត់ផ្សែងខ្មៅនោះរសាត់អស់ ។ រហាត់ខ្យល់បានក្លាយទៅជាផេះ !

ទិដ្ឋភាពនេះហាក់ដូចជាលើកទឹកចិត្តដល់សត្វទាំងអស់ ។ សេចក្ដីភិតភ័យ និងការអស់សង្ឃឹមអម្បាញ់មិញបានក្លាយទៅជាកំហឹងប្រឆាំងនឹងអំពើដ៏ក្រខ្វក់និងថោកទាបនេះទៅវិញ ។

សម្រែកសងសឹកបានលាន់ឡើងនៅគ្រប់មាត់ ហើយ

ដោយគ្មានបង្អង់រង់ចាំបញ្ជាពីគេ សត្វទាំងអស់រត់ស្រាព្រាត គ្នាតំរង់ទៅរកសត្រូវ ដោយពុំបានគិតដល់គ្រាប់កាំភ្លើងដែលរត់ប្រសាចមកលើវាដូចជាព្រិលនោះឡើយ ។ ជាការប្រយុទ្ធមួយដ៏សាហាវព្រៃផ្សៃបំផុត ។ មនុស្សគិតតែពីបាញ់ សត្វចេះតែរត់សំរុកចូលទៅ ។ ការប្រយុទ្ធខ្លួនទល់និងខ្លួនក៏ចាប់ផ្ដើម ។ មនុស្សយកដំបងរំពាត់និងស្បែកជើងវាយវាត់ឥតមានបង្អង់ដៃ ។ មេគោមួយ ពពែបី និង ក្ងានពីរត្រូវស្លាប់នឹងកន្លែង ចំណែកឯសត្វឯទៀតត្រូវរបួសយ៉ាងដំណំគ្រប់ ៗ គ្នា ។ អាឈ្មុះដែលដឹកនាំប្រតិបត្តិការសឹកនៅពីក្រោយបានត្រូវគ្រាប់កាំភ្លើងមួយគ្រាប់ចំកន្ទុយ ។ មនុស្សក៏ត្រូវរបួសខ្លះដែរ ។ បីនាក់ត្រូវអាព្រូញចាក់ចំក្បាលម្នាក់មួយជើងយ៉ាងខ្លាំង ។ ម្នាក់ទៀតត្រូវធ្លាយពោះដោយត្រូវស្នែងមេគោរ័ត ។ ម្នាក់ទៀតត្រូវមីប្រេចនិងមីពេះខាំត្រូវចាក់រហូតដល់ដាច់ដោចខោអាវអស់រលីង ។

សំណាងល្អរបស់សត្វ ក្នុងពេលនោះ អាឆ្កែទាំងប្រាំបួន ៗ ដែលជាសេនាផ្ទាល់របស់អាឈ្មុះរត់ស្រព្រមគ្នាចេញពីរបងតំរង់ទៅរកមនុស្ស ។ ដល់ហើយ វាក៏ស្រែកសម្រុក ៗ ដ៏ឡមនុស្សទាំងនោះហាក់ដូចជាមានក្រវមផាន់តក់ស្លុតគ្រប់ ៗ គ្នា ។



លុះឃើញថា ខ្លួនត្រូវព័ទ្ធជុំវិញដោយវត្ថុសាហាវ ពូយៀងក៏ស្រែកប្រាប់គីគ្គា ឲ្យរត់ក្នុងពេលដែលអាសន្នខ្លាំងមិនទាន់មកដល់ ។ រួចពូយៀងនិងគីគ្គាគាត់រត់យកព្រះអាយុរៀង ៗ ខ្លួន ។ ឃើញដូច្នោះ សត្វទាំងអស់ក៏ដេញរហូតដល់ចុងស្រែ ។ វាឆ្លៀតឱកាសទាត់និងចាក់ចំមនុស្សខ្លះក្នុងពេលដែលគេរត់ក្បៀលចូលរបង ។

សត្វឈ្នះហើយ! តែវាត្រូវរបួសហើយអស់កម្លាំងច្រើន។ វាចូលមកក្នុងភូមិវិញដោយហត់ហេវ ។ វាឃើញសត្វខ្លះដេកស្លាប់នៅលើវាលស្មៅ ។ ទិដ្ឋភាពដ៏សង្វេគនេះធ្វើឲ្យវាទប់ទឹកភ្នែកមិនបាន ។ វាដើរមកឈរប់នៅកន្លែងរហាត់ខ្យល់រួចនៅស្ងៀមដោយក្រៀមក្រំក្នុងចិត្តយ៉ាងក្រៃលែង ។

ត្រូវហើយ រហាត់ខ្យល់បានរលាយទៅជាផេះ! កម្លាំងដែលវាបានសន្សំក៏បានរលាយខ្សុះបាត់ទៅជាមួយដែរ ។ គ្រឹះរហាត់បានត្រូវខ្ទេចខ្ទីគ្មានសល់ ។ ហើយបើវាដាច់ចិត្តនឹងសង់ឡើងជាថ្មីម្ដងទៀត វាក៏មិនអាចយកថ្មដែលបែកនេះមកប្រើប្រាសបានទៀតឡើយ ។ ថ្មបែកខ្ចាត់ខ្ចាយអស់គ្មានសល់ដោយកម្លាំងផ្ទុះនៃរំសេវ ។ រហាត់ខ្យល់ត្រូវខ្ទេចរាបស្មើនឹងដី មើលទៅដូចជាគ្មានអ្វីត្រូវបានសង់នៅកន្លែងនេះពីកាលមុនមកឡើយ ។

ហុះដើរចូលបកជិតភូមិ អាប្រាជ្ញដែលគេមិនឃើញសោះពេលមានវិបត្តិនេះ ក៏ដើរតំរង់ទៅរកបង្អួចស្តូបកក្នុយចុះឡើងដោយបីតិត្រេកអរ ។ ក្នុងពេលនោះស្រាប់តែឮស្នូរកាំភ្លើងមួយចេញពីដង្រុក ។

"តើអាគណាបាញ់អីទៀត?" អាព្រួញសួរ

"ដើម្បីទទួលជ័យជំនះរបស់យើង" អាប្រាជ្ញឆ្លើយភ្លាម

"ជ័យជំនះអ្វី?" អាព្រួញសួរ ។ អាព្រួញត្រូវរបួសជួនកៅជើង ។ ក្រចកជើងវាបាក់និងប្រេះបែកជាពីរ ព្រមទាំងមានគ្រាប់កាំភ្លើងប្រហែល ១២ គ្រាប់បានកប់ក្នុងជើងវាផង ។

"តើជ័យជំនះលើនរណាអាសម្លាញ់?"

"យើងបានដេញខ្មាំងចេញពីភូមិ ដែលជាកន្លែងដីជាទីស្រឡាញ់របស់យើង"

"តែវាបានបំផ្លាញរហាត់ខ្យល់ ដែលយើងបានខំសាងបកអស់ពេលជាង ២ ឆ្នាំហើយ" ។

"មិនអីទេ យើងនឹងសាងរហាត់មួយថ្មីទៀត ។ យើងនឹងសាងរហាត់ប្រាំមួយទៀត បើសិនជាយើងត្រូវការ! តើអាសម្លាញ់ឯងមិនជឿលើកម្លាំងរបស់យើងទេឬអី? កន្លែងដែលយើងកំពុងឈរនេះ ពីមុនវានៅក្នុងកណ្ដាប់ដៃខ្មាំង



សត្រូវ ក្រោយការដឹកនាំនៃសម្លាញ់ណុះ យើងបានដណ្ដើមយកវិញហើយ!" អាព្រួញបន្ថែមថា: "ដូច្នេះយើងបានបកវិញទាំងអស់" "ហ្នឹងហើយដែលគេហៅថាជ័យជំនះ" អាប្រាជ្ញបញ្ជាក់ថែម ។

ថាហើយ សត្វទាំងអស់ដើរចូលក្នុងភូមិ ។ គ្រាប់ដែលកប់ក្នុងជើងអាព្រួញធ្វើឲ្យវាឈឺចាប់ជាខ្លាំង ។ វានឹកឃើញដល់កិច្ចការដ៏លំបាក បើសិនជាវាត្រូវសង់រហាត់ជាថ្មីម្ដងទៀត ។ ហើយម្ដងណោះទៀតវាក៏នឹងមិនគេចវេះពីកិច្ចការនេះដដែល ។ ក៏ប៉ុន្តែវានឹកទៅដល់អាយុវាដែលឥឡូវចូលដល់ ១១ ឆ្នាំហើយ ។ វាបារម្ភខ្លាចក្រែងកម្លាំងវាពុំបានខ្លាំងដូចកាលមុន ។

ក្រោយពីបានឃើញទង់ពណ៌បៃតង ត្រូវបង្ហូតឡើងវិញលើបង្គោល ក្រោយពីបានឮស្នូរកាំភ្លើងបាញ់ ៧ ដង និងក្រោយពីបានស្ដាប់សុន្ទរកថា របស់អាឈ្មុះ ដែលបានរៀបរាប់សរសើរពីសេចក្ដីក្លាហានរបស់ពួកវា សត្វទាំងអស់ហាក់ដូចជាជឿថា វាបានជ័យជំនះមែន ។ សត្វដែលបានស្លាប់ក៏ត្រូវបានយកទៅធ្វើបុណ្យយ៉ាងអឹកធឹក ។ អាព្រួញនិងមីកណ្ដូបសេះ អូសរទេះខ្មោច ចំណែកអាឈ្មុះដើរពីមុខក្បួនដង្ហែ ។ វាធ្វើបុណ្យពីរយប់ពីរថ្ងៃមានចំរៀង - សុន្ទរកថា

ចាញ់ការកើង-ចែករំលោភផលសត្វគ្រប់ ៗ គ្នា ។ សត្វនិមួយ ៗ ត្រូវបានផ្លែឈើមួយ-គ្រាប់ពោតពីរក្តាប់សំរាប់សត្វស្លាប និងសាច់ ១ ដុំសំរាប់ឆ្កែនិមួយ ៗ ។ អាណ្ឌុះបានប្រកាសថានឹងប្រសិទ្ធិប្រយុទ្ធទើបនិងរួចហើយនេះថា “ប្រតិបត្តិការសឹករហាត់ខ្យល់” ព្រមទាំងបានបង្កើតគ្រឿងឥស្សរិយយសមួយទៀតហៅ “ពិជ័យសង្គ្រាម” សំរាប់ខ្លួនវា ។ ការសប្បាយក្រោយពីចំបាំងឈ្នះបានធ្វើឲ្យសត្វទាំងអស់ភ្លេចនូវរឿងក្រដាស់ប្រាក់បន្លំរបស់ពួយៀង ។

ប៉ុន្មានថ្ងៃក្រោយមក ពួកជ្រូកបានរកឃើញឥទិនស្រាដែលគេលាក់ចោលក្រោមផ្ទះ ពូស្ងិត ហើយគ្មាននរណាបានប្រទះភ្នែកសោះ ។ យប់នោះគេឮសម្លេងស្រែកហ៊ោសប្បាយចេញពីផ្ទះ ។ នរណាក៏ភ្ញាក់ផ្អើលនឹងសម្លេងនេះដែរព្រោះវាដូចជាចម្រៀងបទ “បដិវត្តន៍” ។ ប្រហែលជាម៉ោង ៩ កន្លះយប់នោះ គេឃើញអាណ្ឌុះលួចចេញពីទ្វារក្រោយពាក់មួកកញ្ចាស់មួយរបស់ពូស្ងិតរត់បោលលេងជុំវិញទីធ្លារួចហើយក៏ចូលទៅក្នុងវិញ ។

ព្រឹកឡើង សភាពស្ងៀមស្ងាត់យ៉ាងចំឡែកបានគ្របដណ្តប់លើភូមិសម្រែង ។ ជ្រូកស្ងាត់ឈឹងគ្មានឮមាត់ ។ ប្រហែលជាម៉ោងបាំបួន ទើបគេឃើញអាប្រាជ្ញដើរចេញមក



ដំណើរព្រេតព្រាត ដូចជារស់កញ្ជ្រង ក្អែកស្អិតស្អក់-កន្ទុយធ្លាក់ចុះមកក្រោម ។ អាប្រាជ្ញដូចជាមានជម្ងឺធ្ងន់ ។ វាហៅសត្វទាំងអស់ឲ្យមកប្រជុំ ព្រោះវាមានដំណឹងមួយដ៏ក្រៀមក្រំនឹងប្រាប់ ៖

“ឥឡូវរៀបចំឡងបដិវត្តន៍របស់យើងឈឺធ្ងន់!”។ សម្រែកយំក៏បានលាន់ឮរំពងឡើង ។ វានាំគ្នាយកចំបើងមកក្រាលនៅមុខទ្វារជង្រុក ហើយនាំគ្នាដើរចេញមកដាក់ជើងថ្នម ៗ ហាក់ដូចជាមិនចង់ឲ្យឮសូរអ្វីដែលអាចរំខានដល់អាណ្ឌុះ ។ វាយំខ្សឹកខ្សួល ព្រមទាំងដណ្តឹងសួរគ្នាទៅវិញទៅមកអំពីអនាគតរបស់វាថា បើសិនជាមេដឹកនាំរបស់វានឹងចាកចោលវាទៅនោះតើវានឹងទៅជាយ៉ាងណា ? ។ មានពាក្យចចាមអារាមលេចឡើងថា អាសំឡីបានប្រើស្នៀតយកថ្នាំបំពុលដាក់លាយក្នុងចំណីអាណ្ឌុះ ។ ម៉ោង ១១ ថ្ងៃដដែល អាប្រាជ្ញចេញមកក្រៅ ព្រមទាំងនាំដំណឹងមួយទៀតមកប្រាប់ថា នៅពេលចុងក្រោយនេះ អាណ្ឌុះបានចេញបទបញ្ញត្តិមួយទៀតគឺហាមសត្វទាំងអស់មិនឲ្យផឹកស្រា ហើយបើសត្វណាប្រព្រឹត្តផ្ទុយពីបទបញ្ជានេះ នឹងត្រូវទោសប្រហារជីវិត ។

ល្ងាចឡើង ដំណឹងឮថា ជម្ងឺអាណ្ឌុះបានធូរបន្តិចទើង

វិញ ។ ស្អែកឡើង អាប្រាជ្ញចេញមក ប្រាប់ថាអាឈ្មុះគាត់តែបានស្រួលឡើងវិញហើយ ។ ល្ងាចថ្ងៃនោះ គេឃើញអាឈ្មុះមកធ្វើការ ។

មួយថ្ងៃក្រោយមក វាបានបញ្ជាហៅពូ "ពាង" ដើម្បីពឹងគាត់ឲ្យរកទិញសៀវភៅនិយាយពីរបៀបបិទស្រា ។

មួយអាទិត្យក្រោយមក អាឈ្មុះបានបញ្ជាឲ្យយកដីមួយដុំនៅក្បែរចំការដែលពីមុនវាគិតថាទុកធ្វើក្រោលឲ្យសត្វណាធ្វើការលែងកើតទៅសំរាកនោះ មកប្រើការផ្សេងវិញ ។ វាបញ្ជាឲ្យគេភ្ជួររាស់កន្លែងនេះ ក្នុងគោលបំណងថានឹងដាំស្មៅទៀតព្រោះស្មៅកាន់តែក្រឡើងៗ ។ តែទីបំផុតសត្វទាំងអស់ដឹងថា អាឈ្មុះបានយកដីកន្លែងនោះសំរាប់ដាំស្រូវធ្វើស្រាទៅវិញ ។

ក្នុងពេលនេះ មានវិបត្តិមួយកើតឡើងទៀត ដោយគ្មាននរណានឹកនាសោះ ។ យប់មួយប្រហែលកណ្ដាលអធ្រាត គេឮសូរសម្លេងដូចជាមានអ្វីធ្លាក់ចេញពីជង្រុក។ សត្វទាំងអស់ក៏រត់ចេញពីក្រោល ។ យប់នេះជាយប់ខែភ្លឺ ។ នៅក្រោមជញ្ជាំងជង្រុក ដែលមានចារទុកនូវមាត្រាទាំងអស់នៃធម្មនុញ្ញ វាឃើញមានជណ្ដើរមួយធ្លាក់ជាពីរ ។ អាប្រាជ្ញរត់ត្រង់ទៅកន្លែងនោះ ដួលធ្លាក់ស្មារតីដោយសេចក្ដីភ្ញាក់ ព្រោះវា



ឃើញនៅកន្លែងនោះមានគោមមួយ ជក់លាបថ្នាំ និងកំប៉ុងថ្នាំស ដែលមានថ្នាំកំពប់ពាសពេញដី ។ ហ្វូងឆ្កែរត់ទៅព័ទ្ធជុំវិញអាប្រាជ្ញ ហើយក៏ត្រាវាចូលផ្ទះវិញមួយរំពេច ។

គ្មានសត្វណាមួយឡើយ យល់ពីឧបទ្ទវហេតុដែលទើបនឹងកើតឡើងនេះ ក្រៅពីអាភ្លើដែលចេះតែងក់ក្បាលចុះឡើង ហាក់ដូចជាយល់រឿងនេះ តែមិនហ៊ានចេញស្ដីអ្វីឡើយ ។

ជាច្រើនថ្ងៃក្រោយមក មីភ្លុកដើរចូលទៅក្នុងជង្រុកឈរមើលធម្មនុញ្ញ ហើយភ្ញាក់ខ្លួនឯងថា មានមាត្រាខ្លះដែលសត្វទាំងឡាយបានយល់ច្រឡំទាំងអស់ ។

កាលពីមុន សត្វទាំងអស់ចាំបានយ៉ាងច្បាស់ថា មាត្រា៥បានចែងថា៖ "សត្វមិនត្រូវផឹកស្រា" ។ តែមានពាក្យពីរបីម៉ាត់ទៀតដែលវាមិនចាំ ។ ឥឡូវនេះវាឃើញថា មាត្រា៥បានចែងថា៖

"សត្វមិនត្រូវផឹកស្រាឲ្យហួសកំរិត" ។

## ជំពូក ៩

ក្រចកជើងអាព្រួញដែលបែកចេញជាពីរ ឥឡូវបានជាសះស្បើយហើយ ។ សត្វទាំងអស់បានចាប់សង់រហាត់ខ្យល់ជាថ្មីម្តងទៀត ក្រោយពីបានរៀបចំពិធីសម្ពោធជោគជ័យប្រតិបត្តិការសឹករួច ។ អាព្រួញមិនដែលទុកថ្ងៃណាឲ្យទំនេរទេ ហើយដើម្បីរក្សាកិត្តិយសនិងសំដីរបស់វា វាមិនចង់ឲ្យអ្នកណាដឹងថា វាធ្វើការទាំងបង្ហឺទៀតផង ។ ជួនកាលល្ងាចឡើងទើបវាលាន់មាត់ប្រាប់មីកណ្តូបសេះថា ជើងវានៅចុកពើតនៅឡើយ ។ មីកណ្តូបសេះខំដើររកឫសឈើនិងស្មៅយកមកទំពាហើយព្រួសដាក់កន្លែងឈឺ ។ អាភ្លីនិងមីកណ្តូបសេះចេះតែអង្វរកុំឲ្យវាខំប្រឹងធ្វើការច្រើនពេក: " សួងត្រូវដឹងថាយើងមិនមែនស៊ូទ្រាំបានរហូតទេ " ។ នេះជាពាក្យដាស់តឿនរបស់មីកណ្តូបសេះ តែអាព្រួញហាក់ដូចជាមិនព្រមស្តាប់ ។ វាប្រាប់ទៅវិញថា វត្ថុបំណងតែមួយរបស់វា គឺវាចង់បានឃើញរហាត់ខ្យល់មុនពេលដែលវាធ្វើការលែងកើត។

ក្រោយពីបដិវត្តន៍ សត្វទាំងអស់នៅចាំបានថាច្បាប់ចូលនិវត្តន៍សម្រាប់សេះនិងជ្រូកគឺ១២ ឆ្នាំ គោ ១៤ ឆ្កែ ៩ ពពែ ៧



មាន់និងក្ងាន ៥ ឆ្នាំ ។ ផ្ទះសម្រាប់សម្រាកដល់ពេលធ្វើការលែងកើតក៏ប្រុងនឹងសង់ដែរ ។ តែរហូតមកដល់ពេលឥឡូវ ពុំទាន់មានសត្វណាមួយនៅឡើយទេ ដែលបានត្រូវអនុញ្ញាតឲ្យឈប់ធ្វើការ ថ្វីបើសត្វទាំងអស់ជជែកគ្នាតែពីរឿងនេះក៏ដោយ ។ ឥឡូវដីដែលថាទុកសម្រាប់ដាំស្រូវដំណេកឹបក៏បានរៀបចំក្តួររាស់រួចស្រេចហើយ ។ មានដំណឹងមួយទៀតលេចឮថានៅជ្រុងវាលមួយនោះ អាឈ្មោះបានបញ្ជាឲ្យព័ទ្ធរបងជុំវិញ ដើម្បីទុកសំគាល់កន្លែងសម្រាប់សង់រោងសម្រាកជាគុរង្វាន់ដល់សត្វណាដែលបានចូលវ័យជរាហើយ ដែលធ្វើការលែងកើត ។ ឮថាសម្រាប់សេះ ត្រូវបានគ្រាប់ពោត ៣ គីឡូ ឬចំបើង ៨ គីឡូ ក្នុងមួយថ្ងៃ ព្រមទាំងបានផ្លែឈើផងនៅថ្ងៃបុណ្យ ។ អាព្រួញជិតចូលអាយុ ១២ ឆ្នាំហើយ នៅចុងរដូវប្រាំងក្រោយ ។

ជីវភាពរស់នៅកាន់តែតឹងតែង ការងារក៏កាន់តែពិបាក។ ធាតុអាកាសមិនល្អសោះឆ្នាំនេះ ម្ល៉ោះហើយស្បៀងក៏កាន់តែខ្សត់ទៅ ។ ចំណីសម្រាប់សត្វនិមួយៗត្រូវបន្ថយ លើកលែងតែសម្រាប់ជ្រូកនិងឆ្កែ ។ អាប្រាជ្ញខំពន្យល់ឲ្យសត្វទាំងអស់យល់ថា ការបែងចែកចំណីឲ្យបានស្មើៗគ្នាជាការពិបាកធ្វើហើយថែមទាំងផ្ទុយនឹងគំនិតបដិវត្តន៍ទៀតផង ។ ហើយ

នៅក្នុងពេលនេះទៀតពាក្យចចាមអារ៉ាមដែលថា មានការខ្វះខាតចំណីនិងស្បៀងអាហារនោះជាពាក្យមិនពិតទេ ។ បើសិនជាមានការខ្វះខាតបន្តិចចំណីក៏មិនត្រូវបន្ទោសដែរ ហើយការណ៍ដែលសត្វទាំងអស់បានទទួលម្ហូបតិចជាងពីមុននោះ គឺមកពីការរៀបចំថ្មី ដើម្បីឲ្យកាន់តែបានប្រសិទ្ធិភាពក្នុងការចែកចំណីតែប៉ុណ្ណោះ ។ អាប្រាជ្ញយកស្ថិតិមកបង្ហាញចំពោះមុខសត្វទាំងអស់ព្រមទាំងពន្យល់ថាសព្វថ្ងៃនេះ សត្វទាំងអស់បានទទួលគ្រាប់ពោត ចំបើងផ្លែឈើ មើមឈើច្រើនជាងមុន ទឹកផឹកក៏កាន់តែមានរសជាតិ អាយុកាន់តែវែង។ សត្វដែលទើបនឹងកើតក៏មិនសូវជួបប្រទះនឹងការស្លាប់ ស្មៅក៏កាន់តែសម្បូរ ហើយឯជម្ងឺក៏កាន់តែតិចទៅ ។ សត្វទាំងអស់ជឿអាប្រាជ្ញគ្រប់ម៉ាត់ ព្រោះតាមការពិតវាភ្លេចជីវិតរស់នៅកាលជំនាន់មុនបដិវត្តន៍អស់ទៅហើយ ។ វាដឹងថាសព្វថ្ងៃជីវិតកាន់តែពិបាកនិងវេទនា ប្រកបទៅដោយការស្រេកឃ្លាន ខ្វះការកក់ក្ដៅ ហើយតម្រូវឲ្យធ្វើការគ្រប់ពេលវេលាលើកលែងតែពេលដេក ។ ពិតប្រាកដហើយ វាបានរងកម្មនិងវេទនាកាលពីជំនាន់មុន ដូច្នេះវាសប្បាយចិត្តណាស់កាលបានឮថាជីវិតនឹងបានធូរស្រាលក្នុងបច្ចុប្បន្ននេះ ។ ម៉្យាងទៀតកាលពីមុនវាជាខ្ញុំបម្រើរបស់មនុស្ស តែឥឡូវវាមានសេរីភាព ។



ត្រង់នេះហើយដែលជាចំណុចសំខាន់ដែល អាប្រាជ្ញបានយកមកបង្ហាញនិងពន្យល់ ។

សព្វថ្ងៃចំនួនសត្វកាន់តែកើនឡើង ។ ខែមុនមេជ្រូក ៤ បានសម្រាលកូន ៣១ ក្បាល ។ កូនជ្រូកទាំងអស់មានពណ៌ប្រផេះ ហើយនៅក្នុងភូមិមានជ្រូកបាតែមួយគត់គឺអាល្មុះ ។ ដូច្នេះហើយគេអាចទាយបានថា កូនជ្រូកនេះកាត់ទៅរកអ្នកណា ។ មានដំណឹងមួយទៀតធ្វើឲ្យលេចឮថា អាល្មុះបានបញ្ជាឲ្យទិញឥដ្ឋនិងឈើ ដើម្បីសង់សាលារៀនមួយនៅក្នុងទីធ្លា ។ ក្នុងពេលដែលមិនទាន់មានសាលា កូនជ្រូកទាំងឡាយបានទទួលការហ្វឹកហ្វឺនផ្ទាល់ពីអាល្មុះ នៅក្នុងរោងបាយ ។ វាហាត់ប្រាណនៅក្នុងសួនហើយត្រូវហាមមិនឲ្យប្រឡែងលេងជាមួយសត្វដទៃទៀតទេ ។ មានបទបញ្ញត្តិមួយទៀតចែងថា កាលណាជ្រូកនិងសត្វដទៃទៀតដើរជួបគ្នា សត្វទាំងនោះត្រូវចៀសផ្លូវឲ្យជ្រូកទៅមុន ហើយជ្រូកទាំងអស់គ្រប់ជាន់ថ្នាក់ ត្រូវចងបូរពណ៌បៃតងនៅកន្ទុយរាល់ថ្ងៃអាទិត្យ ។

ឆ្នាំនេះមានដំណើរប្រហែលឆ្នាំមុន លើកលែងតែថវិកាភូមិដែលត្រូវចុះដុនដាបបន្តិច ។ គេត្រូវការទិញឥដ្ឋ ខ្សាច់ កំបោរ សម្រាប់សង់សាលារៀន ព្រមទាំងសម្ភារៈ

ផ្សេងទៀតសម្រាប់កោតឡក់ ។ គេត្រូវការទិញប្រេង រុជ ទៀននិងស្ករសម្រាប់ប្ដូរអាណ្ណុះ ។ អាណ្ណុះបានហាម មិនឲ្យជ្រូកដទៃទៀតស៊ីស្ករទេ ព្រោះវាថាស្ករធ្វើឲ្យបាត់ផល ប្រយោជន៍ ។ គេក៏ត្រូវការទិញប្រដាប់ប្រដារ ដូចជាដែក គោល ខ្សែ ត្បូង លួស ដែក និងចំណីផ្សេងៗ ទៀត ។ ចំបើង និងបើបឈើមួយដុំគត្រូវទុកដើម្បីលក់ ។ រីឯពងមាន់ក៏ត្រូវ លក់ច្រើនជាងមុនដែរ គឺ ៦០០ ពងក្នុងមួយអាទិត្យ ។ ម៉្លោះ ហើយចំនួនមេមាន់កាន់តែតិចទៅៗ ព្រោះមេមាន់គ្មានពងនឹង ក្រាប ។ ចំណីដែលត្រូវបន្ថយពីរបីខែមកហើយនោះ ឥឡូវក៏ ត្រូវបន្ថយថែមទៀត ។ ភ្លើងជង្រុកក៏ត្រូវឈប់អុជព្រោះគេ ចង់សន្សំប្រេងទុកប្រើនៅពេលមានអាសន្ន ។ ចំណែកពួក ជ្រូក នៅតែមានជីវភាពដូចធម្មតា ។ តាមពិតទៅវាកាន់ តែធាត់ជាងមុនផង ។ ល្ងាចមួយគេធុំក្លិនឈ្ងុយចំឡែក ហើយដែលសត្វទាំងឡាយមិនដែលស្គាល់ផង ។ ក្លិននេះ ចេញពីរោងបិទស្រាតូចមួយ ដែលនៅឆ្ងាយបន្តិចពីផ្ទះបាយ ហើយជាកន្លែងដែលពូស៊ិតបានទុកចោលឥតប្រើប្រាស់ជា យូរមកហើយ ។ សត្វខ្លះថាក្លិននេះជាក្លិនគេដាំបាយ ។ វាទាំងអស់គ្នាហិតក្លិននេះដោយស្រេកឃ្លាន ហើយសង្ឃឹម ថាគេធ្វើម្ហូបពិសេសសម្រាប់វាហើយ ។ ចាំទៅ ៗ



ម្ហូបពិសេសនោះអត់មាន ហើយស្រាប់តែមានដំណឹងមួយ ឮដឹងថាចាប់តាំងពីថ្ងៃនេះតទៅជ្រូកត្រូវតែស៊ីបាយ ។ ឥឡូវដីចំណេរជាច្រើនត្រូវដាំស្រូវតែត្រូវដំណើរ ហើយ ជ្រូកនិមួយៗត្រូវបានស្រាបួយកំប៉ុងក្នុងមួយថ្ងៃ ។ ចំណែក អាណ្ណុះត្រូវបានស្រា ២ លីត្រ ក្នុងមួយថ្ងៃ សម្រាប់តែមួយជា មួយស៊ុប ។

ថ្វីបើកិច្ចការដ៏លំបាកមានកាន់តែច្រើនឡើងក៏ដោយ ក៏ការ រស់នៅសព្វថ្ងៃហាក់ដូចជាមានភាពថ្លៃថ្នូរខ្លះដែរ ។ ឥឡូវ គេឃើញមានចម្រៀង សុន្ទរកថា ការដង្ហែក្បួន ។ តាម បញ្ជាថ្មីរបស់អាណ្ណុះ ត្រូវមានបាតុកម្មដែលហៅថាពិធីដង្ហែក្បួនក្នុង មួយអាទិត្យម្ដងដើម្បីរំលឹកពីជ័យជម្នះនៃកសិដ្ឋានសត្វ នៅថ្ងៃអាទិត្យ ក្នុងពេលធ្វើបាតុកម្មនេះ គេសង្កេត ឃើញសត្វទាំងអស់ដើរជាក្បួនទាហានដើរតាមជ្រូកដើរមុខ គេ បន្ទាប់មកសេះ គោ រួចមកមេមាន់និងទា ក្មេងៗដើរមកក្រោយ ហើយមួកដើរបោះអាវុធខ្មៅរបស់អាណ្ណុះ ទង់ពណ៌បៃតងដែលមានសញ្ញាជើងសេះនិងស្នែងនិងអក្សរ ស្លោកដែលមានសេចក្ដីថា ជយោ អាណ្ណុះ ។ បន្ទាប់ពីការដង្ហែក្បួន មានសូត្រកំណាព្យសរសើរ

នាំ និងការផ្លុំត្រែគរសោរដោយសារក្រោធឡើងរាល់ពិធីស្មិត នៃការចំរើនហើយផ្លុកការ មានការបាញ់កាំភ្លើងផង ។ ក្រុមពពែចូលចិត្តនិងខ្នះខ្នែងជាងគេក្នុងការសំដែងក្បួននេះ ។ សត្វខ្លះពោលត្អូញត្អែរត្អូញត្រូវទាស់នឹងបាតុកម្ម កាលណាក្ដារថ្ងៃក្តៅនិងត្រជាក់នៅផិតវា ។ រាល់ផងដែលមានការរៀបទាំងពីរឿងសព្វួរក្បួន ដោយឃើញថាជាការនាំឲ្យខាតពេលនិងអស់កម្លាំង ព្រោះត្រូវឈរយាប់យ៉ាងចំរាំដែលចប់កម្មវិធីនោះ ពួកពពែក៏នាំគ្នាស្រែកសន្ធាប់ឲ្យសត្វទាំងនោះបាត់មាត់ ព្រមទាំងស្រែកពាក្យស្លោក : “ជើងបួនល្អ ជើងពីរអាក្រក់” ទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញថាសត្វភាគច្រើនចូលចិត្តនឹងបាតុកម្ម ព្រោះបាតុកម្មអាចរំលឹកនិងដាស់សតិវាគ្រប់គ្នាឲ្យចាំជានិច្ចថាឥឡូវនេះវាជាម្ចាស់ខ្លួនវា ហើយហើយកិច្ចការទាំងប៉ុន្មានដែលវាធ្វើគឺដើម្បីប្រយោជន៍វាទាំងអស់ ។ ហើយយ៉ាងហោចណាស់ក៏ចម្រៀង ក្បួនស្ថិតិ សូរកាំភ្លើង សម្លេងមាន់រងាវ ទង់ដែលបក់រវិច អាចធ្វើឲ្យវាទាំងអស់គ្នាភ្លេចមួយដងមួយកាលនូវការស្រេកឃ្លាន និងទុក្ខវេទនាទាំងឡាយនោះ ។

ខែមេសាចូលមកដល់ ។ ភូមិសម្រែងបានត្រូវប្រកាសជាផ្លូវការជាសាធារណរដ្ឋ ។ ដូច្នេះការជ្រើសរើស



ប្រធានាធិបតីក៏កើតមានឡើងដែរ ។ ដោយមានបេក្ខជនតែម្នាក់គត់នោះអាឈ្មុះក៏ត្រូវតែងតាំងជាឯកច្ឆន្ទជាប្រធានាធិបតីទីមួយ ។ ក្នុងថ្ងៃដដែលនោះ គេបានរកឃើញឯកសារថ្មីៗទៀត ស្តីពីការសមគំនិតរបស់អាសំឡីជាមួយពូស្មិតដែលជាចៅហ្វាយចាស់ ។ ឥឡូវសត្វទាំងអស់ហាក់ដូចជាចង់ជឿថា អាសំឡីវាមិនត្រឹមតែមិនចង់ឲ្យការប្រយុទ្ធនៅពេលប្រតិបត្តិការសឹកសម្រែងជ័យ បានស័យជំនះប៉ុណ្ណោះទេ តែវាថែមទាំងបានចូលដៃជាមួយសត្រូវទៀតផង ។ តាមការពិត គឺអាសំឡីនេះហើយដែលជាមេក្លោងខាងសត្រូវ ព្រោះវាបានស្រែកយ៉ាងពេញមាត់ថា “ជោគជ័យចូរមានដល់មនុស្សជាតិ !” ។ ហើយរបួសនៅលើខ្នងអាសំឡីដែលសត្វទាំងអស់នៅចាំបាននោះ គឺវាត្រូវអាឈ្មុះខាំនឹងធ្មេញទៅវិញទេ ។

នាកណ្ដាលរដូវប្រាំង គេឃើញអាខ្វកក្អែកសាំងរបស់ពូស្មិតហើរចូលមកក្នុងភូមិ ។ គេមិនដែលឃើញអានេះច្រើនឆ្នាំមកហើយ ។ រូបរាងនិងអាកប្បកិរិយាឥតផ្លាស់ប្ដូរទេ គឺថាវានៅតែខ្ជិលហើយចូលចិត្តនិទានអំពី “ភ្នំស្ករ” ។ វាហើរទៅទំលើគល់ឈើ ទទះស្លាបហើយចាប់និទានរឿងដែលគ្មានចុងគ្មានដើម ។ ឲ្យតែសត្វណាមួយស្តាប់វា វា

ក៏ចាប់សាវស័ព្ទភ្លាម : " នៅលើភ្នំនោះអាសប្បាញ់ ! វាពោលឡើងដោយម៉ឺងម៉ាត់ ព្រមទាំងយកចំពុះវាចង្អុលទៅលើមេឃ— នៅលើនោះហើយពីក្រោយដុំពពកដែលអ្នកឃើញនោះ គឺភ្នំស្ករ: ។ ភ្នំនោះជាកន្លែងហោមហាសប្បាយ ព្រោះនៅទីនោះហើយ ដែលសត្វទាំងឡាយអាចរស់យ៉ាងសុខសាន្តនៅពេលចូលវ័យជរាធ្វើការលែងកើត " ។ វាអួតប្រាប់សត្វទាំងអស់ថា មានថ្ងៃមួយដែលវាហើរទៅដល់កំពូលភ្នំនោះ វាបានឃើញវាលស្មៅដីធំធេងដាច់កន្ទុយភ្នែក និងស្ករដុំ រាយពាសពេញលើមែកឈើ ។ សត្វភាគច្រើនជឿវាទាំងអស់ ។ វាយល់ឃើញថា បើសព្វថ្ងៃវាមានការលំបាកនិងស្រេកឃ្លាន វាត្រូវតែមានភពមួយទៀតដែលសប្បាយដូចភ្នំស្ករ:នេះ ។ តែគេមិនដឹងថា តើពួកជ្រូកយល់យ៉ាងណាទេ ចំពោះសំដីអាខ្មូកនេះ ព្រោះអ្វីៗដែលអាខ្មូកនិយាយសុទ្ធសឹងតែជារឿងភូតភរទាំងអស់ ។ ក៏ប៉ុន្តែពួកជ្រូកនៅតែអនុញ្ញាត ឱ្យអាខ្មូកសំណាក់នៅក្នុងភូមិដោយឥតបង្ខំឱ្យធ្វើការអ្វីសោះ ព្រមទាំងបំប៉នស្រាឱ្យវាមួយកំប៉ុងរាល់តែថ្ងៃទៀតផង ។

ឥឡូវក្រចកជើងអាព្រួញ បានជាសះស្បើយហើយ ។ វាធ្វើការកាន់តែច្រើនលើសមុន ។ ឯសត្វដទៃទៀតក៏ធ្វើការ



ស្ទើរបាក់កម្លាំងដែរឆ្នាំនេះ ។ ក្រៅពីកិច្ចការធម្មតាក្នុងស្រែចំការនិងការសង់រហាត់ខ្យល់ វាត្រូវសង់សាលារៀនសំរាប់កូនជ្រូក ។ កិច្ចការនេះបានចាប់ធ្វើតាំងពីខែមីនាមកម៉្លេះ ។ តែបើនៅតែទទួលចំណីមិនគ្រប់គ្រាន់ ព្រមទាំងធ្វើការយ៉ាងនេះតទៅទៀត មើលទៅសត្វទាំងអស់មិនអាចទ្រាំទ្របានទេ លើកលែងតែអាព្រួញដែលមិនចេះថ្ងូរនិងគេចវេះម្តងណាឡើយនោះ ។ វាតែងតែប្រាប់គេឯងថា ដូចជាមិនទាន់មានសញ្ញាអ្វីបញ្ជាក់ឱ្យឃើញថាកម្លាំងវានឹងអន់ថយសោះ បើកុំនិយាយអំពីសភាពខាងក្រៅដែលបានប្រែប្រួលបន្តិចបន្តួចដូចជាឥឡូវស្បែកនិងរោមមានសម្បុរស្រអាប់ មិនភ្លឺរលោងដូចមុន ចង្កេះទាំងសងខាងហាក់ដូចជាបាក់ ។ សត្វខ្លះជឿថា កម្លាំងអាព្រួញនឹងស្ទុះមកវិញនៅរដូវស្មៅខ្ចីខាងមុខនេះ ។ ឥឡូវស្មៅខ្ចីដុះពាសពេញវាលទៅហើយ តែអាព្រួញនៅតែមានសភាពដដែល ។ នៅពេលវារុញដុំថ្មធំៗ ឡើងលើទួល ដើម្បីទម្លាក់មកក្រោមឱ្យបែកជាដុំតូចៗ ម្តងៗ គេឃើញកម្លាំងវាកាន់តែថយហើយខ្សោយជាងទម្ងន់ថ្ម តែគ្មានអ្វីមករារាំងកម្លាំងចិត្តនិងសេចក្តីមាន:វាបានឡើយ ។ នៅពេលនោះគេឃើញមាត់វាហើបមួបៗ ហាក់ដូចជាចង់ថា: " អញនឹងខំធ្វើការឱ្យកាន់តែច្រើន " តែគ្មានអ្នកណាឮសំដី

វាឡើយ ។ ជារៀយៗ មីកណ្តុបសេះនិងវាតែងប្រាប់ឲ្យវាខំថែរក្សាកម្លាំងបន្តិច ក៏ប៉ុន្តែអាព្រួញធ្វើជាមិនឮ ។ ឥឡូវអាយុវាជិតចូល១២ឆ្នាំហើយ ។ វាឥតរវីរវល់នឹងពាក្យចាស់តឿននរណាទាំងអស់ ក្រៅពីខំអូសថ្មទៅបំបែកឲ្យបានច្រើន មុននឹងដល់ថ្ងៃចូលនិវត្តន៍ ។

នាល្ងាចមួយនៃរដូវប្រាំង មានដំណឹងមួយលេចឮពេញភូមិថាអាព្រួញបានទៅអូសថ្មម្នាក់ឯង ។ ពាក្យចចាមអារាមនេះប្រែជាពិតទៅវិញ ព្រោះបីបួននាទីក្រោយមកស្រាប់តែមានព្រាបពីរហើរសំដៅមកភូមិហើយប្រាប់ថា: "អាព្រួញបានធ្លាក់ពីលើទួល ឥឡូវដួលផ្ងារពោះក្រោកមិនរួចទេ" ។

លុះបានឮដូច្នោះហើយ សត្វទាំងឡាយក៏នាំគ្នារត់សំដៅទៅរកកន្លែងកើតហេតុ ។ វាឃើញអាព្រួញដួលផ្ងារពោះមែន ក្បាលជាប់ក្នុងការកង់រទេះ កំរើកខ្លួនមិនរួច ភ្នែកស្លឹតស្លាំងញើសបែកជោគពេញខ្លួនទាំងអស់ ឈាមហូរហៀរចេញពីមាត់ ។ ឃើញដូច្នោះ មីកណ្តុបសេះដាក់ខ្លួនចុះជិតអាព្រួញហើយនិយាយថា:

"អាព្រួញ យ៉ាងម៉េចដែរក្នុងខ្លួនឯង?"

"អញឈឺដើមទ្រូងណាស់" - អាព្រួញឆ្លើយតបដោយសម្លេងខ្សាវៗ - "តែមិនអីទេ អញជឿថាអ្នកអាចបង្ហើយ



រលោកខ្សាច់បានដោយមិនបាច់មានអញ ។ ឥឡូវថ្មក៏បានផ្គួនអស់ច្រើនណាស់ហើយ ។ បើគិតទៅនៅតែ១ខែទៀតអញនឹងបានចូលនិវត្តន៍ ។ រីឯអាភ្លើក៏ជិតចូលដែរដូចគ្នា គេមុខជាឲ្យវាសំរាក ព្រោះហើយយើងទាំងពីរមុខជានឹងបានជួបគ្នាដល់ពេលចូលនិវត្តន៍" ។

មីកណ្តុបសេះក៏ស្រែកខ្លាំងឡើងថា: "យើងត្រូវតែជួយវាភ្លាម តើមាននរណាទៅប្រាប់អាប្រាជ្ញទេ?" ។

រំពេចនោះ សត្វខ្លះក៏រត់ទៅភូមិដើម្បីយកដំណឹងទៅប្រាប់អាប្រាជ្ញ ។ មីកណ្តុបសេះនិងអាភ្លើទំរេតខ្លួនក្បែរអាព្រួញ ហើយយកកន្ទុយបក់រុយឲ្យវាដោយស្ងាត់ស្ងៀម ។ បន្តិចមកអាប្រាជ្ញក៏មកដល់ដោយទឹកមុខអាណិតនិងបារម្ភ ។ វាប្រាប់ថាអាឈ្មុះបានដឹងពីរឿងនេះអស់ហើយ ហើយមានសេចក្តីព្រួយព្រមទាំងចង់រំលែកទុក្ខនៃកម្មអាក្រក់ ដែលបានកើតឡើងលើរូបអាព្រួញ ដែលជាសមាជិកស្លូតត្រង់មួយរូបនេះណាស់ ។

ឥឡូវនេះ អាឈ្មុះក៏បានបញ្ជាឲ្យរៀបចំយកអាព្រួញទៅកាន់មន្ទីរព្យាបាលឯផ្សារ ។ សត្វទាំងអស់មានសេចក្តីបារម្ភច្រើនក្រោយពីបានឮសំដីនេះ ។ ក្រៅពីមីប្រផេះនិងអាសំឡី គ្មានសត្វណាមួយទេដែលធ្លាប់ចេញពីភូមិ ។ វាទាំងអស់

ភ្នាបិនចង់ឃើញសម្លាញ់វាណាមួយ ដែលមាន ជម្ងឺ ហើយ ត្រូវបញ្ជូនឲ្យទៅរស់នៅក្នុងកណ្ដាប់ដៃនៃមនុស្សឡើយ ។ តែអាប្រាជ្ញបានពន្យល់ថានៅឯផ្សារ គេមានមន្ទីរពេទ្យព្យាបាលសត្វដែលអាចមើលជម្ងឺអាព្រួញបានល្អជាងទុកឲ្យវានៅក្នុងភូមិ ។

ប្រហែលជាពីរម៉ោងក្រោយមក អាព្រួញក៏បានស្រួលខ្លួនបន្តិច ។ វាទំប្រឹងក្រោកឈរហើយត្រដររដើរទៅភូមិវិញ ។ មីកណ្ដុបសេះនិងអាភ្លើបានយកចំបើងមករៀបចំកន្លែងដេកយ៉ាងស្រួលសម្រាប់ទទួលអាព្រួញ ។

ពីរថ្ងៃហើយដែលអាព្រួញដេកឈឺក្នុងក្រោល ។ ជ្រូកបានយកថ្នាំពណ៌ក្រហម ដែលវារកឃើញក្នុងបន្ទប់ទឹកពួស្និត ឲ្យអាព្រួញផឹក ។ មីកណ្ដុបសេះជាអ្នកបញ្ចុកថ្នាំអាព្រួញពីរដងក្នុងមួយថ្ងៃក្រោយពេលបាយម្ដង ។ ហើយរាល់ល្ងាចគេឃើញវាដេកហើយនិយាយលេងជាមួយអាព្រួញ ។ ចំណែកអាភ្លើវិញ គេឃើញវាដេកបក់រុយឲ្យអាព្រួញ ។ អាព្រួញចេះតែពោលថាកុំឲ្យនរណាពិបាកចិត្តនឹងវា ហើយបើវាជាពីជម្ងឺវាអាចរស់នៅ ៣ ឆ្នាំទៅមុខទៀត ។ វានឹកដល់ពេលដែលវានឹងបានសំរាក ហើយចំរេគខ្លួនទៅលើវាលស្មៅដ៏ធំតេង ។ ពេលនោះហើយដែលវានឹងឆ្លៀតឱកាស



រៀននិងគិត ។ វាប្រុងប្រាស្រេចថានឹងប្រើពេលនោះដើម្បីរៀនតួអក្សរទាំងប៉ុន្មានដែលវាមិនទាន់ចេះ ។

អាភ្លើនិងមីកណ្ដុបសេះមកសួរសុខទុក្ខវានៅក្រោយពេលធ្វើការ ។ ថ្ងៃមួយនៅពេលថ្ងៃត្រង់ គេឃើញរទេះមួយចូលមកបំរុងដឹកវាយកទៅពេទ្យ ។ សត្វទាំងអស់កំពុងដោចស្មៅនៅចំការ ក្រោមការត្រួតត្រានៃពួកជ្រូក ស្រាប់តែពេលនោះ គេឃើញអាភ្លើរត់យ៉ាងលឿនចេញពីក្រោល ស្រែកយ៉ាងភ្លាត់សម្លេង ។ ជាលើកដំបូងហើយ ដែលគេឃើញអាភ្លើចេះខឹងហើយផាយយ៉ាងលឿនដូច្នេះ ។ “ឆាប់ឡើង ឆាប់ឡើង” – វាស្រែក – មកភ្លាម គេនឹងមកដឹកយកអាព្រួញហើយ” ។ ដោយពុំចាំបាច់មានបញ្ជាពីជ្រូក សត្វទាំងអស់ក៏បញ្ឈប់កិច្ចការភ្លាមហើយរត់តំរង់ទៅភូមិមួយរំពេច ។ ដល់ហើយវាឃើញរទេះទ្រុងមួយអូសដោយសេះពីរ ។ ទ្រុងនោះមានសរសេរអក្សរនៅគ្រប់ជ្រុង ហើយមានតាម្នាក់ប្រកបដោយទឹកមុខមិនគួរឲ្យទុកចិត្តនិងពាក់មួកផង អង្គុយនៅកន្លែងបរ ។ អាព្រួញបានចេញបាត់ពីក្រោលហើយ ។ សត្វទាំងឡាយឈរជុំវិញរទេះ ហើយស្រែកថា៖ “ទៅឲ្យបានសុខ ទៅឲ្យបានឆាប់ជា សម្លាញ់!” ។ “អាចំកួត – អាភ្លើស្រែកសន្ធាប់ឡើងព្រមទាំងយកជើងទន្រ្ទាំដីផង – អាចំកួត

តើឯងមិនគិតមើលអក្សរដែលសរសេរលើទ្រុងនោះទេឬអី?"

ឮដូច្នោះសត្វទាំងអស់ឈប់បាត់មាត់ដោយស្ងៀបស្ងាត់។ មីក្ដុកខំប្រកបអក្សរ ។ អាត្តើច្រានវាចេញហើយដំរេក់មួយសន្ទុះធំ ទើបវាបញ្ចេញពាក្យឡើងថា: "ហាងលក់ស្បែក តើឯងរាល់គ្នាយល់ថាអាហ្នឹងជាស្អីទេ? គេយកអាព្រួញទៅលក់ឱ្យចិនព្រលះស្បែកហើយ!"

សត្វទាំងអស់ស្រែកឡើងដោយភិតភ័យ ។ ពេលនោះតាអ្នកបររទេះ ក៏លើករំពាត់វាយសេះ ហើយរទេះក៏ចាប់រុលទៅមុខចេញពីភូមិ ។ សត្វទាំងអស់ស្រែកបណ្ដើរ រត់តាមបណ្ដើរ ។ មីកណ្ដូបសេះរត់មុនគេមុនឯងនៅខាងមុខ ។ រទេះកាន់តែលឿនឡើងៗ ។ មីកណ្ដូបសេះខំផាយយ៉ាងលឿនឱ្យទាន់រទេះ ។

"អាព្រួញ! វាស្រែក- អាព្រួញ! អាព្រួញ! អាព្រួញ!" ។ ដោយឮសម្លេងអ៊ូអរនៅខាងក្រៅ អាព្រួញក៏ងើតតាមចន្លោះបង្អួចខាងក្រោយ ។ គេឃើញតែឆ្នូតស ដែលនៅចុងច្រមុះរបស់វា ។ "អាព្រួញ!" មីកណ្ដូបសេះតែខំស្រែក "អាព្រួញឆាប់រត់ចេញមក ចេញឆាប់ទើង គេយកឯងទៅសម្លាប់ហើយ!"

សត្វទាំងអស់ក៏ស្រែកព្រមគ្នាថា: "ចេញមក អាព្រួញ



ចេញមក" តែរទេះកាន់តែបរលឿនឡើងៗ ហួតផាច់ឆ្ងាយពីហ្វូងសត្វទាំងឡាយ ។ គេមិនដឹងថា តើអាព្រួញស្ដាប់ពាក្យមីកណ្ដូបសេះបានឬមិនបានទេ ។ តែមួយសន្ទុះក្រោយមក គេលែងឃើញមុខអាព្រួញតាមចន្លោះបង្អួចហើយ ស្រាប់តែឮស្នូរជើងទន្ទ្រាំពេញទាំងទ្រុង ។ គេដឹងដូច្នេះថាអាព្រួញចង់បំរាស់ចេញពីទ្រុង ។ វាខំយកជើងធាក់ទ្រុងឱ្យរហែក ក៏ប៉ុន្តែគួរឱ្យអនិច្ចា! កម្លាំងវាស្បើយអស់រលីងហើយ មួយស្របក់មកស្នូរជើងក្ដុងក្ដាំងដែលចេញពីទ្រុងអម្បាញមិញ ក៏ស្ងាត់បាត់សូន្យឈឹង ។ ដោយអស់សង្ឃឹមសត្វទាំងអស់ក៏នាំគ្នាស្រែកអង្វរសេះទាំងពីរ ដែលកំពុងទាញរទេះនោះឱ្យឈប់: "សម្លាញ់-សម្លាញ់" វាស្រែកព្រមគ្នា "អ្នកកុំយកគ្នាយើងទៅឱ្យគេសម្លាប់!" ។

ក៏ប៉ុន្តែសត្វទាំងពីរនោះស្ដាប់មិនបាន ព្រោះល្ងង់ ហើយមិនយល់គ្រាន់តែឮហើយ ក៏កាន់តែបង្កើនចង្វាក់ជើងរត់ទៅទៀត ។ មុខអាព្រួញបាត់ពីចន្លោះបង្អួចទៅហើយ ។ ហួសហើយ គ្មាននរណានឹកនាមុនសោះថាបើសិនជារត់ឱ្យលឿនទៅជិតទ្វាររបងប្រហែលជាជួយកើត ។ ឥឡូវរទេះបោលផុតទ្វាររបងទៅហើយ ហើយសំដៅយ៉ាងលឿនទៅកាន់ផ្លូវធំ ។ គេលែងឃើញមុខអាព្រួញទៀតហើយ ។

បីថ្ងៃក្រោយមក គេបានដំណឹងថាអាព្រួញបានស្លាប់នៅឯពេទ្យ ទោះបីជាវាបានត្រូវគេថែទាំយ៉ាងល្អិតល្អន់ជាងសេះណាៗទាំងអស់ក៏ដោយ ។ អាប្រាជ្ញបានផ្សាយដំណឹងនេះដល់សត្វទាំងអស់ ។ វាប្រាប់សត្វទាំងអស់ថាវាបាននៅជិតអាព្រួញរហូតដល់ដង្ហើមចុងក្រោយ ។

"គួរឲ្យស្រណោះនិងអាណិតវាណាស់ — អាប្រាជ្ញពោលឡើងដោយលើកយកជើងមួយបកជូតទឹកភ្នែក — អញនៅជិតវារហូតដល់វាផុតដង្ហើម ។ នៅនាទីចុងក្រោយបង្អស់ វាខំនិយាយតែមិនចេញសោះ ម្ល៉ោះហើយវាខ្សិបដាក់ត្រចៀកអញថា វាស្ដាយតែម្យ៉ាងទេ គឺថាវាស្លាប់មុនវាបានឃើញរហាត់ខ្យល់បានសម្រេច ។ ទៅមុខទៀតសម្មាញ់! ទៅមុខទៀត 'ដើម្បីបដិវត្តន៍របស់យើង!

ជយោ សត្វទាំងអស់!

ជយោ រៀមច្បងបដិវត្តន៍!

មិត្តឈ្មុះ មិនដែលធ្វើអ្វីខុស!

នេះហើយជាពាក្យចុងក្រោយដែលវាផ្ដាំ សម្មាញ់!" ។

ទឹកមុខអាប្រាជ្ញប្រែភ្លាម គ្រាន់តែនិយាយរួច ។ វានៅស្ងៀមភ្នែកសម្លឹងចុះឡើងហាក់ដូចជាមិនទុកចិត្តលើអ្វីមួយ រួចហើយវាក៏ដើរចេញទៅ ។ វានៅចាំបានអំពីភាពចលាចល



ពោរពេញទៅដោយកំហឹង ក្នុងពេលដែលមនុស្សមកដឹកយកអាព្រួញចេញពីភូមិទៅ ។ សត្វខ្លះបានឃើញទ្រុងនោះសរសេរអក្សរពីក្រៅថា: "ហាងលក់ស្បែក" ហើយគេទាំងអស់មុខជាគិតថា អាព្រួញត្រូវគេយកទៅលក់ឡចិនសម្លាប់យកស្បែកហើយ ។ វាដូចជាមិនទឹកដល់រឿងនេះសោះ ។ ឱ! មកពីសត្វទាំងនោះវាល្ងង់ពេក ។ ភ្លាមនោះវាស្រែកយ៉ាងខ្លាំងដោយគ្រវាត់កន្ទុយ និងដើរចុះឡើងថា: "ចូរឯងទាំងអស់គ្នាបានជំនឿលើការសម្រេចរបស់មេដឹកនាំយើងចុះ! ពិតហើយរទេះនោះជារបស់ហាងលក់ស្បែក តែពេទ្យសត្វគេបានទិញយកទៅប្រើ ហើយអក្សរនោះគេពុំទាន់បានលុបចោល ។ ដូច្នេះហើយបានជាឯងទាំងអស់គ្នាយល់ច្រឡំនោះ" ។

នេះជាពាក្យពន្យល់យ៉ាងងាយស្រួលរបស់អាប្រាជ្ញ ។

សត្វទាំងអស់ធូរចិត្តបន្តិចកាលបានស្ដាប់អាប្រាជ្ញពន្យល់ ។ ហើយដល់វារៀបរាប់អំពីជម្ងឺរបស់អាព្រួញ ការថែទាំយ៉ាងយកចិត្តទុកដាក់នៅក្នុងមន្ទីរពេទ្យ ថ្នាំល្អៗ ដែលអាឈ្មុះបានបញ្ជាឲ្យយកទៅជួយព្យាបាលដោយឥតគិតអំពីតម្លៃ ការងឿងឆ្ងល់និងសេចក្ដីគុកក្ដួលទាំងប៉ុន្មានក៏រសាយអស់ភ្លាម ។ វាទាំងអស់ត្រឡប់ទៅជាសប្បាយទៅវិញកាលណាបានឮថា

សម្លាប់វាយ៉ាងឃោរឃៅ ក៏បានស្តាប់ដោយគេយកចិត្តទុកដាក់ណាស់ដែរ ។

ព្រឹកថ្ងៃអាទិត្យអាឈ្មុះចេញមកប្រជុំហើយធ្វើសុន្ទរកថាមួយសរសើរពីអាព្រួញ ។ វាថាវាមិនអាចយកខ្មោចអាព្រួញមកកប់ក្នុងភូមិបានទេ ព្រោះមានឧបសគ្គផ្សេងៗ តែវាបានបញ្ជាឱ្យគេធ្វើកម្រងផ្កាមួយយ៉ាងល្អ យកទៅដាក់លើផ្នូរវារួចហើយ ។ ហើយក្នុងពីរបីថ្ងៃទៀតវាមានបំណងនឹងធ្វើបុណ្យឡៀងមួយដើម្បីរំលឹកវិញ្ញាណក្ខន្ធអាព្រួញ ។ អាឈ្មុះបញ្ចប់សុន្ទរកថាដោយ ស្រែកនូវពាក្យស្លោករបស់អាព្រួញ "អញនឹងធ្វើការឱ្យកាន់តែច្រើន មិត្តឈ្មុះមិនដែលធ្វើខុស" ព្រមទាំងឃោសនាឱ្យសត្វទាំងអស់យកតម្រាប់តាមអាព្រួញផង ។

ថ្ងៃបុណ្យមកដល់ហើយ ។ គេឃើញរទេះមួយបរចូលមកក្នុងភូមិ ដឹកប្រអប់មួយធំ ដែលដាក់សុទ្ធតែរបស់ស៊ីនិងផ្លែឈើ ។ យប់ឡើងគេឮសូរសម្លេងស្រែកហ៊ោរកញ្ជ្រៀវហាក់ដូចជាឈ្លោះគ្នា ព្រោះដូចជាសម្លេងដែលគេចោលកែវឱ្យបែកខ្ទេចខ្ទី ។ សម្លេងនោះស្ងប់ទៅវិញនៅម៉ោង ១១ យប់ ។ ស្អែកឡើងរហូតដល់ថ្ងៃត្រង់គេពុំឃើញសត្វណា



មួយចេញមកក្រៅឡើយ ។ មានពាក្យចចាមអារាមថាពួកជ្រូកបានទិញស្រាវិស្គីមួយឡាំងធំសម្រាប់ទុកស៊ីផឹក ដោយគេមិនដឹងសោះថាតើវាបានលុយមកពីណា ។

# ជំពូក ១០

ខែក្ដៅចេះតែកន្លងទៅ ។

រដូវវស្សាចូលមកហើយផុតទៅទៀតបន្តបន្ទាប់គ្នា ។ ជីវិតសត្វដ៏ខ្លីក៏ផ្លាស់ប្ដូរ អន្ទោលទៅតាមគ្នាដែរ ។ រហូតមកដល់ឥឡូវនេះគ្មានសត្វណាមួយឡើយ ក្រៅពីមីកណ្ដុបសេះ អាភ្លើ - អាខ្វកនិងជ្រូកខ្លះ ដែលនៅចាំបានពីព្រឹត្តការណ៍មុនថ្ងៃបដិវត្តន៍ ។

មីភ្លុកពពែស ដែលជាសត្វល្ងង់តែស្លូតត្រង់ ស្លាប់បាត់យូរហើយ ។ មេឆ្កែទាំងបីគឺមីព្រុះ - មីស្រេច - និងមីល្អុង ក៏បានអស់ជីវិតដែរ ។ ចំណែកពូស្មិតដែលជាជនអភ័ព្វ ហើយត្រូវគេបណ្ដេញចោលព្រោះចិត្តកំណាច និងអយុត្តិធម៌ ក៏ជៀសមិនផុតពីកង់ជីវិតដែរ ។ គាត់បានស្លាប់ដោយរោគប្រមឹក នៅភូមិមួយដាច់ស្រយាលពីភូមិសម្រែង។ គ្មាននរណាមួយនឹកទេពីវាសនារបស់អាសំឡី - ជ្រូកដែលខំជួយបដិវត្តន៍ តែទីបំផុតត្រូវគេចោទថាក្បត់នឹងគំនិតបដិវត្តន៍វិញ - រហូតដល់គេដេញចោលបាត់ឈ្មោះ បាត់រូប ។ អាព្រួញ — សេះដែលបានបូជាជីវិតដើម្បីប្រយោជន៍រួម —



ល្ងង់ហើយ ធ្វើការតែមានប្រតែកម្លាំងកាយនោះ ចិត្តស្មោះត្រង់ឥតមានក្នុងមានក្រៅ — រហូតដល់ស្លាប់ក្នុងកណ្ដាប់ដៃនឹងកបេណ្ដៀចនៃចៅហ្វាយដែលវាខំបំរើ និងប្ដូរជីវិតឲ្យពុំមាននរណានឹកនារឭពីវាសោះ ក្រៅពីសម្លាញ់ចាស់ៗ វាពីរ-បីនាក់ប៉ុណ្ណោះ ។ ឥឡូវមីកណ្ដុបសេះទៅជាមេសេះកញ្ចាស់មួយដែលមានដៃជើងជ្រីវជ្រួញ ស្បែកគគ្រាតគគ្រើម - ភ្នែកស្អិតស្អក់ដូចកើតគ្រុនចាញ់ ។ វាគួរតែបានច្បាប់សំរាក ពីរឆ្នាំមកហើយ ។ តែតាមការពិតគ្មានសត្វណាមួយបានឈប់សំរាកឡើយ ។ គំរោងការដែលចង់ទុកដីមួយជ្រុងក្នុងវាលស្រែដើម្បីសង់រោងសំណាក់ឲ្យសត្វចូលនិវត្តន៍នោះ ក៏ត្រូវគេបំភ្លេចចោលយូរយ៉ាររណាស់មកហើយ ។ សព្វថ្ងៃមានតែអាឈ្មុះទេដែលមានទម្ងន់ជិតបីហាប ។ ចំណែកអាប្រាជ្ញក៏ធាត់ណាស់ដែរ ។ វាធាត់ពេកទាល់តែភ្នែកវាទាំងពីរលិចអស់ស្ទើរមើលមិនឃើញ ។ ចំណែកអាភ្លើដែលជាលាល្ងង់ហើយឆោត ដូចជានៅដដែលដូចមុន - ខុសប្លែកបន្តិចតែត្រង់ច្រមុះ ហើយតាំងពីអាព្រួញស្លាប់មកទឹកមុខវាចេះតែស្រងូតស្រងាត់មិនសូវនិយាយស្ដីអ្វីសោះ ។

គេនៅឃើញមុខចំឡែក ៗ ទៀតនៅក្នុងភូមិ តែចំនួនក៏មិនច្រើនជាងឆ្នាំមុនដែរ ។ សត្វភាគច្រើនដែលបានកើត

មកហើយ ពួកគេនិយាយប្រាប់ពីបដិវត្តន៍ពីមាត់មួយទៅមាត់មួយ ។ ឯសត្វខ្លះទៀតដែលគេទិញយកមកពីក្រៅគ្មានបានដឹងឮអ្វីសោះពីរឿងនេះ ។ ឥឡូវក្រៅពីបីកណ្ដុបសេះ គេឃើញមានសេះថ្មីបីទៀត ។ វាជាពូជសេះល្អ មានរាងរៅមាំជាសត្វធ្វើការនិងមានសណ្ដាប់ធ្នាប់ល្អគួរទុកជាគ្នាបាន តែមានមុខមាត់ដូចជាមិនឆ្លាត ។ ក្នុងចំណោមសេះទាំងបីនេះ គ្មានអាណាមួយអាចរៀនហើយចាំ តួអក្សរឲ្យហួសពីអក្សរ "ខ" ឡើយ ។ វាជឿទាំងអស់អ្វីៗដែលគេនិយាយប្រាប់ពីបដិវត្តន៍ ពីច្បាប់ធម្មនុញ្ញ ។ ជាពិសេសវាជឿទាំងស្រុងលើមីកណ្ដុបសេះ ដែលវាទាំងបីគោរពនិងកោតខ្លាច ។ តែគេមិនដឹងថាតើអាសេះទាំងបីនេះ យល់អំពីន័យ នៃបដិវត្តន៍នេះឬយ៉ាងណាដែរ ។ ភូមិកាន់តែចំរើន ការរៀបចំក៏កាន់តែត្រឹមត្រូវឡើង ។ ឥឡូវទីដីភូមិបានវាតទំហំកាន់តែធំបន្តិច ដោយបានស្រែពីរទៀត ដែលត្រូវបានទិញពីពូថងផ្ទាប់ជាមួយ ។ សំណង់រហាត់ខ្យល់ក៏បានហើយស្រេចបាច់ ។ ឥឡូវភូមិក៏មានម៉ាស៊ីនបេះនិងប្រឡះពោត ម៉ាស៊ីនគើបចំបើងព្រមទាំងមានសង់រោងជាច្រើនបន្ថែមទៀត ។ ពូពាងបានទិញរទេះផ្ដួមួយថ្មីទៀត ។ ថ្វីបើរហាត់ខ្យល់ត្រូវបានសង់រួចហើយក៏ដោយ ក៏គេពុំបានយកវាទៅប្រើឲ្យបង្កើតចរន្ត



អគ្គិសនីដូចបានគ្រោងទុកទេ ។ អាណ្ហុះបញ្ជាឲ្យទុកប្រើសំរាប់កិនពោតធ្វើជាបញ្ញើទៅវិញ ។ យ៉ាងណាមិញកំរៃក៏បានចូលមកក្រាស់ក្រែលដែរ ។ ដូច្នេះសត្វទាំងអស់ត្រូវសាងរហាត់ខ្យល់មួយទៀត ។ ម្ដងនេះ វាបំរុងនឹងទុកឲ្យបង្កើតចរន្តអគ្គិសនី ។ ការសប្បូរសប្បាយមួយ ដែលអាសំព្វីខំឃោសនាឲ្យសត្វទាំងអស់ផ្ដេកសេចក្ដីសង្ឃឹមលើ ដូចជាមានភ្លើងនៅគ្រប់ក្រោល មានទឹកក្ដៅទឹកត្រជាក់ ធ្វើការបីថ្ងៃមួយអាទិត្យ គ្មាននរណាមួយតំណាលពីរឿងនេះទៀតឡើយ ។ អាណ្ហុះបានហាមមិនឲ្យនិយាយរឿងនេះ ព្រោះវាថាជាគំនិតប្រឆាំងនឹងឧត្ដមគតិនៃសត្វនិយម ឯសុភមង្គលដ៏ពិតប្រាកដនោះ គឺនៅត្រង់ធ្វើការច្រើន និងមានបាយស៊ីគ្រប់គ្រាន់ ។

តាមពិតភូមិសប្រែងកាន់តែសប្បូរសប្បាយមែន ក៏ប៉ុន្តែសត្វទាំងឡាយដូចជាមានជីវិតរស់នៅធម្មតា ដូចពីមុន លើកលែងតែជ្រូកនិងឆ្កែ ។ នេះប្រហែលមកពីមានជ្រូកនិងឆ្កែច្រើនជាងសត្វដទៃទៀត ហើយសត្វទាំងពីរប្រភេទនេះឥតបានធ្វើការអ្វីឡើយ ។ អាប្រាជ្ញនៅតែខំពន្យល់ថា ជ្រូកថ្វីបើគេមិនធ្វើការហត្ថកម្មមែន តែគេត្រូវប្រើកម្លាំងប្រាជ្ញា ក្នុងការចាត់ចែងការ និងរៀបចំគំរោងការថ្មីសម្រាប់ភូមិ ។

ការងាររបស់វាពិបាក ព្រោះហើយសត្វដែលល្ងង់មិនអាចនឹងយល់ ហើយធ្វើកើតឡើយ ។ អាប្រាជ្ញពន្យល់ទៀតថា ជ្រូកត្រូវបំពេញកិច្ចការកំប៉ិកកំប៉ុក ហើយស្មុគស្មាញរាល់ថ្ងៃ ដូចជារៀបចំ "ផុសស៊ុយេ" ធ្វើសេចក្តីកត់ហេតុ ចាត់ចែងរបៀបវារៈ និងកិច្ចការផ្សេងៗទៀត ។ វាសុទ្ធតែសំណុំរឿងសំខាន់ៗ ដែលគ្មានសត្វណាឡើយត្រូវដឹង - ហើយជួនកាលបើរឿងនោះវាសំងាត់ពេក គេត្រូវដុតចោលក្នុងចង្ក្រានបាយ ។ វាជាអាយុជីវិតនៃការចំរើនលូតលាស់របស់ភូមិ អាប្រាជ្ញចេះតែខំនឹករកពាក្យពន្យល់ ។ ដូច្នេះគ្មានជ្រូកឬឆ្កែណាមួយឡើយដែលធ្វើការហត្ថកម្ម ហើយសព្វថ្ងៃនេះ គេឃើញមានតែជ្រូកនិងឆ្កែទេ ដែលមានការស៊ីចុកកាន់តែប្រសើរឡើងៗ ។

ចំពោះសត្វដទៃ បើតាមវាដឹងការរស់នៅឥតមានផ្លាស់ប្តូរអ្វីបន្តិចឡើយ ។ វានៅតែជួបសេចក្តីស្រេកឃ្លាន ដេកលើចំបើង ផឹកទឹកក្នុងត្រពាំង និងត្រូវធ្វើស្រែចំការ ឥតពេលសំរាកដដែល ។ នៅរដូវត្រៀងវាធុញទ្រាន់នឹងទឹក ភក់ ដោតជាំ នៅរដូវក្តៅវិញវាត្រូវរំខានដោយរុយ ។

សត្វចាស់ៗចេះតែនាំគ្នាខំគិត ហើយនឹកទៅដល់អនុស្សាវរីយចាស់ៗ ជំនាន់មុនបដិវត្តន៍ នឹកដល់ថ្ងៃដែលពូស្មិត



ត្រូវគេបណ្តេញចេញពីភូមិ ។ តើពេលនោះជីវិតវាប្រសើរឬវេទនាជាងឥឡូវ ? វាភ្លេចអស់ ។ វាមិនអាចយកអ្វីមកប្រៀបធៀបជាមួយជីវិតបច្ចុប្បន្ននេះបានឡើយ ។ មើលទៅគ្មានអ្វីចំរើនសោះ ក្រៅពីស្ថិតិរបស់អាប្រាជ្ញ ដែលចេះតែឡើងរហូតនោះ ។ វាអស់បញ្ញោបាយនឹងដោះស្រាយហើយ ។ តែវាក៏គ្មានពេលនឹងគិតដែរ ។ មានតែអាភ្លើទេ ដែលថាវានៅចាំបានទាំងអស់ រឿងរ៉ាវចាស់ៗ ដែលបង្ហាញឱ្យឃើញថាជីវិតគឺការស្រេកឃ្លាន លំបាក ទុក្ខ ព្រួយ ល្អ អាក្រក់ សុខ ទុក្ខ ដែលជាច្បាប់ទូទៅនៃធម្មជាតិ ។

ប៉ុន្តែសត្វទាំងអស់ពុំទាន់អស់សេចក្តីសង្ឃឹមទេ ។ គ្មានពេលម្តងណាឡើយ ដែលវាមិននឹកដល់ភព្វសំណាងដែលបានកើតមកក្នុងភូមិសម្រែង ។ វាជាភូមិតែមួយគត់ក្នុងប្រទេសទាំងមូល ដែលសត្វមានកម្មសិទ្ធិផ្ទាល់ និងត្រួតត្រាដោយសត្វគ្នាឯង ។ នរណាក៏ដោយ អាតូចទើបនឹងកើត ក៏ដូចជាអាដែលមកពីក្រៅចំងាយ ១០ ឬ ២០ គ.ម ទ្រាំមិនរួចសរសើរពីភូមិសម្រែងនេះមិនកើតឡើយ ។ ពេលដែលវាឮស្នូរកាំភ្លើង និងទង់ពណ៌បៃតងបក់រវិចលើបង្គោលម្តងៗ វាទាំងអស់រំភើប និងត្រេកត្រអាលក្នុងចិត្ត ។ វា

នាំគ្នាចាប់និយាយ ពីផ្លូវដែលពោរពេញដោយគំនិតបដិវត្តន៍ ពីការរំលំរបបមនុស្ស - ពីធម្មនុញ្ញ - ពីប្រតិបត្តិការសឹក និង ពីការចុះចាញ់នៃពួកមនុស្ស ។ គ្មានអ្វីដែលអាចបំភ្លេចបានឡើយ ។

សង្គមថ្មីដែលអា " គំនិត " បានលាតត្រដាងនៅយប់មួយនោះ សង្គមថ្មីដែលបានវាលស្រែពណ៌ខៀវស្រងាត់ដាច់កន្ទុយភ្នែក - សង្គមថ្មីដែលត្រូវត្រួតត្រាដោយសត្វគ្នាឯង ទាំងអស់នេះវាគ្រាន់តែជាសេចក្ដីសង្ឃឹមប៉ុណ្ណោះ ។ ថ្ងៃណាមួយ សេចក្ដីពិតនឹងមកដល់ ។ បើមិនមែនថ្ងៃស្អែកវាក៏មិនយូរលើសពីមួយជីវិតសត្វដែរ ។ ហើយវាជឿជាក់ថាថ្ងៃនោះ គង់តែមកដល់ ។ ចំរៀងបដិវត្តន៍ក៏នៅលួចមានឮឯលិចឯកើត មួយផងមួយយាមដែរ ។ ថ្វីបើសត្វទាំងអស់នៅចាំចំរៀងនេះបានក៏ដោយ ក៏គ្មានសត្វណាមួយហ៊ានច្រៀងឱ្យគេឯងឮឡើយ ។ ជីវិតវាកាន់តែពិបាក - ឯសេចក្ដីសង្ឃឹមវាសាបសូន្យអស់រលីងហើយ ។ តែយ៉ាងណាក៏ដោយ វាក៏នៅជឿថា វាមិនដូចសត្វដែលនៅភូមិដទៃទៀតដែរ ។ បើវាជួបនឹងសេចក្ដីស្រេកឃ្លាន គឺមិនមែនមកពីចំណីនោះយកទៅឱ្យមនុស្សដែលជាចៅហ្វាយនោះទេ ។ វាធ្វើការច្រើន ក៏សម្រាប់បំរើផលប្រយោជន៍របស់វាតែ



ប៉ុណ្ណោះ ។ គ្មានសត្វណាហាក់ដើរជើងពីរដូចមនុស្ស - គ្មានសត្វណាហៅគ្នាឯង " ចៅហ្វាយ " - សត្វទាំងអស់ស្មើគ្នា ។ នេះជាសេចក្ដីពិតនៅភូមិសប្រែង ។

ថ្ងៃមួយនៅរដូវប្រាំង អាប្រាជ្ញបញ្ជាឱ្យហ្វូងពពែដើរតាមវាតំរង់ទៅរកវាលមួយល្ហល្ហេវនៅចុងភូមិ, ដែលមានដុះសុទ្ធតែដើមឈើតូចៗ ។ គេឃើញហ្វូងពពែឈររៀនមើលស្លឹកឈើខ្ចីៗ ក្រោមការដឹកនាំរបស់អាប្រាជ្ញ ។ ល្ងាចឡើងទើបគេឃើញអាប្រាជ្ញត្រឡប់ចូលភូមិវិញ ទុកឱ្យហ្វូងពពែដេកចាំក្រោមដើមឈើនោះ ។ ព្រឹកឡើងទើបគេឃើញអាប្រាជ្ញត្រឡប់ទៅវិញ ។ ពពែដេកស៊ីនៅក្រោមដើមឈើនោះអស់មួយអាទិត្យ ។ សត្វទាំងអស់ក៏ចេះតែឆ្ងល់ ហើយមិនដឹងជាពួកពពែនេះចង់ធ្វើអ្វីនៅទីនោះទេ ។ ក្រោយមកទើបអាប្រាជ្ញប្រាប់គេឯងថា វារវល់ទៅបង្រៀនហ្វូងពពែឱ្យចេះច្រៀងបទថ្មី ហើយវាត្រូវការកន្លែងស្ងាត់ ។

ល្ងាចនេះ មេឃស្រឡះល្អ ។ គេឃើញហ្វូងពពែដើរត្រឡប់ចូលភូមិ ចំពេលដែលសត្វទាំងឡាយទើបនឹងបង្ហើយការងារហើយ ហើយត្រូវចូលមកលំនៅវិញ ។ ពេលនោះស្រាប់តែឮសូរសម្រែកសេះមួយចេញពីទីធ្លា ។ សត្វទាំងអស់ឈប់ង៉ក់ព្រមគ្នា ។ សម្លេងអម្បាញ់មិញជាសម្លេងមី

កណ្ដាបសេះ ។ សម្លេងនេះឮមកទៀត ។ ម្ដងណោះសត្វទាំងអស់ក៏នាំគ្នារត់យ៉ាងលឿនតំរង់ទៅទីធ្លា ។ អនិច្ចា! វាឃើញមីកណ្ដាបសេះ កំពុងតែឈររមើលជ្រូកមួយកំពុងខំប្រឹងហាត់ដើរជើងពីរ ។ ជ្រូកនេះគឺអាប្រាជ្ញ ។ មើលទៅគួរតែអស់សំណើចដោយឃើញវាឈរស្ទើរតែមិនជាប់ ព្រោះទម្ងន់វាធ្ងន់ ។ វាខំប្រឹងដើរជើងពីរកាត់ទីធ្លាទាល់តែបាន ។ មួយសន្ទុះក្រោយមក គេឃើញជ្រូកមួយហ្វូងដើរចេញមកពីទ្វារជង្រុក ។ វាដើរដៅផ្លូវប្រើជើងក្រោយទាំងពីររបស់វា ។ អាខ្លះដើរបានស្រួល — អាមួយពីរទៀតទ្រេតទ្រោតដូចជាត្រូវការចន្ទល់ឬឈើច្រត់ តែវាទាំងអស់ខំប្រឹងដើរបានរហូតដល់ចុងម្ខាងទៀត ។ បន្តិចមកគេឮសូរឆ្កែព្រុះ និងសំរែករងាវនៃអាមាន់ខ្មៅ - រួចទើបគេឃើញអញ្ចុះដើរចេញមក - លើជើងពីរយ៉ាងសង្ហា — ងាកចុះងាកឡើងដៃកាន់រំពាត់ព្រមទាំងមានឆ្កែរត់ជុំវិញខ្លួនវាផង ។

សត្វទាំងអស់ស្រឡាំងកាំងបាត់មាត់ស្ងាត់ឈឹង ។ វាទាំងអស់គ្នាប្រជ្រៀតគ្នៀតគ្នា ដោយសេចក្ដីភិតភ័យនិងងឿងឆ្ងល់ ។ វាសំឡឹងមើលហ្វូងជ្រូកដើរជុំវិញទីធ្លា ហាក់ដូចជាពិភពលោកត្រូវក្រឡាប់ ។ បន្តិចមកសេចក្ដីភ្ញាក់ផ្អើលក៏រសាយទៅវិញ ។ ទោះជាមានសម្លេងគ្រហឹមរបស់ឆ្កែ-



ទោះជាមានទម្លាប់ប្ដូរមកហើយទម្លាប់ដែលមិនដែលត្អូញត្អែរ មិនដែលរិះគន់ — លើអ្វីៗទាំងអស់ — សត្វទាំងអស់រកទប់សំណើចចំអកពុំបានឡើយក្នុងពេលនេះ ។ តែក្នុងពេលនោះហាក់ដូចជាមាននរណាម្នាក់ឱ្យបង្គាប់ ៖ ហ្វូងពពែក៏ចាប់ផ្ដើមស្រែកហ៊ោឡើងព្រមៗគ្នា ៖

"ជើងបួនល្អ-តែជើងពីរក៏កាន់តែប្រសើរ!" ជើងបួនល្អតែជើងពីរក៏កាន់តែប្រសើរ - ជើងបួនល្អ - តែជើងពីរក៏កាន់តែល្អ"

វាស្រែកប្រហែលមួយស្របក់ទើបឈប់ ។ ហើយនៅពេលដែលសម្លេងនេះស្ងប់ទៅ ពួកជ្រូកក៏ដើរចូលទៅក្នុងក្រោល ។ សត្វទាំងអស់ឈរមើលដោយអស់សង្ឃឹម ព្រោះពុំមានឱកាសនឹងនិយាយអ្វីឡើយ ។

អាភ្លើយកច្រមុះត្រដុសលើស្មា ។ វាមើលជុំវិញខ្លួន ។ វាងាកមកឃើញមីកណ្ដាបសេះ ដែលមានភ្នែកកាន់តែងងឹតជាងមុន ។ ដោយឥតចេញស្ដីមួយម៉ាត់ - មីកណ្ដាបសេះក៏យកខ្លួនវារុញអាភ្លើហើយក៏នាំអាភ្លើនេះដើរចូលក្នុងជង្រុក ឈរនៅមុខជញ្ជាំងដែលមានមាត្រាធម្មនុញ្ញចារទុកពីលើ ។ វាទាំងពីរឈរស្ងៀមមួយសន្ទុះធំនៅមុខជញ្ជាំង ដែលមានតួអក្សរពណ៌ស សរសេរពីលើនោះ ។

## "ភ្នែកអញងងឹតទៅហើយ"

មីកណ្ដុបសេះនិយាយឡើង "កាលអញនៅក្មេង អញក៏មិនចេះមើលអក្សរដែរ តែយ៉ាងណាក៏ដោយក៏អញឃើញអក្សរនៅមុខអញនេះដូចជាខុសពីមុន ។ តើមាត្រាប្រាំពីរនៃធម្មនុញ្ញយើងនេះវាដូចពីមុនទេអាភ្នើ?"

អាភ្នើ សុខចិត្តមើលអក្សរដែលសរសេរលើជញ្ជាំង ។ ឥឡូវអ្វីៗទាំងអស់ត្រូវលុបចោលអស់ហើយ នៅសល់តែឃ្លាមួយប៉ុណ្ណោះ ។ ឃ្លានោះសរសេរថា៖

"សត្វទាំងអស់ស្មើគ្នា តែមានសត្វខ្លះត្រូវមានសិទ្ធិលើសសត្វដទៃ" ។

វាគ្មានអ្វីត្រូវឆ្ងល់ទេ ព្រោះស្អែកឡើង សត្វទាំងអស់ចេញទៅធ្វើការ ក្រោមការដឹកនាំនៃជ្រូក ដែលឥឡូវមានរំពាត់កាន់នៅដៃផង ។ វាគ្មានអ្វីឆ្ងល់ទៀតទេ កាលបើបានដឹងថា ឥឡូវជ្រូកមានវិទ្យុស្ដាប់ ។ គេរៀបចំដាក់ទូរស័ព្ទ-និងជាវកាសែតជាច្រើនក្បាលសំរាប់មើល ។ វាគ្មានអ្វីឆ្ងល់ទៀតទេ កាលបើបានឃើញអាឈ្នុះចេញមកដើរលេងយកខ្យល់ក្នុងសួនច្បារ ហើយមានទាំងបៀមខ្សៀរនៅនឹងមាត់ទៀតផង ។ វាគ្មានអ្វីឆ្ងល់ទៀតទេ កាលបើអាឈ្នុះយកខោអាវពូស្មិតមកពាក់ដូចជាអាវកុតខ្មៅ - ខោស្នាប់ភ្លៅ-



ព្រមទាំងស្បែកជើង ។ ចំណែកមេជ្រូកដែលជាជំនិតវាក៏យកអាវស្បៃរបស់ប្រពន្ធពូស្មិតមកពាក់នៅថ្ងៃអាទិត្យដែរ ។

មួយអាទិត្យកន្លងទៅ ។ នៅថ្ងៃរសៀលមួយគេឃើញមានរទេះជាច្រើនបរចូលក្នុងភូមិ ។ នេះគឺអ្នកស្រែនៅជិតខាងភូមិ ដែលបានត្រូវអញ្ជើញមកមើលនិងទស្សនាភូមិ ។ គេទាំងអស់មានសេចក្ដីស្ញប់ស្ញែងនឹងសមិទ្ធិជាច្រើន ដែលបានរីកចំរើន ជាពិសេសរហាត់ខ្យល់ ។ សត្វទាំងអស់កំពុងបោចស្មៅនៅក្នុងចំការ ។ វាខំធ្វើការណាស់ មិនទាំងហ៊ានងើបមុខមើលមុខភ្ញៀវដែលមកមើលផង ។ គេមិនដឹងថាតើសត្វអស់នេះ ខ្លាចជ្រូក ឬខ្លាចមនុស្សទេ ។

យប់នោះ គេឮសូរសម្លេង សប្បាយហ៊ោកញ្ជ្រៀវនិងចំរៀងចេញពីផ្ទះ ។ សត្វនាំគ្នាភ័យ ភ័យនិងងឿងឆ្ងល់នឹងសម្លេងដ៏ចម្លែកនេះ ។ តើវាមានអីកើតឡើងទៀតហើយ ? ។ តើនេះជាលើកដំបូងហើយឬ ដែលសត្វនិងមនុស្សជួបគ្នា ? ដោយស្រុះគ្នា វាទាំងអស់ក៏នាំគ្នាលួនចេញទៅពួនក្នុងសួន។

ទៅដល់មាត់របង - វាឈប់ង៉ក់ ព្រោះចិត្តមួយចង់ត្រឡប់ចូលក្នុងក្រោលវិញ ។ តែទីបំផុតមីកណ្ដុបសេះដាច់ចិត្តនាំផ្លូវ ។ វាទាំងអស់ក៏នាំគ្នាដើរលប ។ ចូលទៅក្នុងផ្ទះ ។ សត្វណាខ្ពស់ ។ ឈរងើបក្បាលតាមចន្លោះបង្អួច ។ វា

ឃើញមនុស្សប្រហែលដប់ពីរនាក់ និងជ្រូកប្រហែលប្រាំមួយរំលងនៅជុំវិញតុវែងមួយ ។ អាឈ្មុះអង្គុយនៅក្បាលតុៈ ដែលជាកន្លែងកិត្តិយស ។ ជ្រូកមានឫកពានឹងទឹកមុខមាំទាំ។ តើវាឃើញអ្វី? វាឃើញមនុស្សនិងសត្វកំពុងលេងបៀយ៉ាងសប្បាយរីករាយបំផុត ។ ឥឡូវគេឈប់សំរាកសិន ដើម្បីផឹកស្រាប្រសិទ្ធិពរ ។ បំពង់ធំមួយកំពុងតែហុចពីដៃមួយទៅដៃមួយ ហើយគេចាក់ស្រាពីបំពង់ធំនោះទៅក្នុងបំពង់តូចៗ ។ គ្មាននរណាមួយយកចិត្តទុកដាក់មើលសត្វដែលកំពុងអើតក្បាល មើលតាមចន្លោះបង្អួចនោះឡើយ ។

គេឃើញពូថងនៃភូមិទួលក្រាំងសៀម ក្រោកឈរកាន់បំពង់ស្រានៅដៃ ។ ប្រហែលបន្តិចទៀតគាត់នឹងសុំឱ្យអ្នកទាំងអស់ផឹកស្រាធ្វើ "តូស្ត" ហើយ ។ តែមុននឹងធ្វើ "តូស្ត" – គាត់បានសុំនិយាយទៅកាន់ភ្ញៀវទាំងអស់សិន ។

គាត់ថា ល្ងាចនេះជាថ្ងៃដ៏ឧឡារិកមួយចំពោះគាត់ និងចំពោះភ្ញៀវទាំងអស់គ្រប់គ្នា ។ ការយល់ច្រឡំ ការមិនទុកចិត្តគ្នា និងការមិនយោគយល់គ្នា ដែលមានជាយូរយារមកហើយនោះត្រូវបានបញ្ចប់ឱ្យរលត់បាត់ទៅវិញនៅល្ងាចនេះ។ ថ្ងៃនេះហើយជាថ្ងៃដែលគាត់និងភ្ញៀវទាំងអស់មករំលែកសេចក្ដីត្រេកត្រអាល ក្រោយពីពេលដែលអ្នកត្រួតត្រាភូមិ



សម្រែងត្រូវអ្នកភូមិជិតខាងបានការច្រណែននិន្ទា មិនទុកចិត្តអស់ពេលជាយូរមក ។ រឿងមិនគួរគប្បីក៏ត្រូវបានលើកឡើង ហើយគំនិតអាក្រក់ក៏បានផុសឡើង សំរាប់ចោទគ្នាទៅវិញទៅមកដែរ ។ គាត់ធ្លាប់ជឿថា ភូមិសម្រែងដែលមានជ្រូកជាអ្នកកាន់កាប់ហើយត្រួតត្រាមុខជាមិនស្រួលហើយ មុខជាបង្កើតនូវសេចក្ដីសៅហ្មងដល់ភូមិជិតខាងជាមិនខាន ។ អ្នកផងជាច្រើនបានទាយទុកជាមុនដោយមិនបានគិតថា នៅភូមិសម្រែងសត្វទាំងអស់មុខតែជួបនូវអាណាធិបតេយ្យ និងការច្របូកច្របល់ទៀតមិនរួច ។ គេទាំងអស់បារម្ភខ្លាចមានផលវិបាកដល់សត្វ និងគ្នីគ្នាគេក្នុងភូមិដទៃទៀត ។ ក៏ប៉ុន្តែការព្រួយបារម្ភនោះបានបាត់អស់ទៅវិញនៅថ្ងៃនេះ ។ ជាពិសេសនៅថ្ងៃនេះ ក្រោយពីបានដើរមើលភូមិសព្វគ្រប់ទៅ គាត់និងមិត្តភក្តិគាត់បានយល់ថាគំនិតមុនៗ សុទ្ធតែខុសទាំងអស់ ។ របៀបធ្វើការយ៉ាងចំរើន និងមានប្រសិទ្ធិភាព វិន័យ ថ្លៃថ្នូរ របៀបរៀបរយ បានធ្វើឱ្យគាត់ចង់យកភូមិសម្រែងជាគំរូដល់ភូមិដទៃទៀត ។ គាត់ហ៊ាននិយាយដោយពេញមាត់ថា សត្វទាំងឡាយនៅភូមិសម្រែងនេះធ្វើការច្រើនតែបានចំណីតិចជាងសត្វទាំងឡាយនៅភូមិដទៃទៀត ។ នេះជាការល្អសំរាប់មនុស្សទៅវិញ ។ ម្ល៉ោះហើយ ក្រោយពីបាន

បើភូមិសប្រែងនេះ គាត់ព្រមនិងមិត្តភក្តិគាត់ នឹងយកគំនិតទាំងអស់ទៅអនុវត្តភ្លាមនៅភូមិរៀងៗខ្លួន ។

គាត់បានបញ្ចប់សុន្ទរកថា ដោយបញ្ជាក់ជាថ្មីម្តងទៀតថា មិត្តភាពត្រូវតែស្ថិតស្ថេរ រហូតទាំងភូមិសប្រែង និងភូមិជិតខាងទាំងអស់ ។ រវាងជ្រូកនិងមនុស្ស មិនត្រូវឲ្យមានការខ្វែងគំនិត និងខ្វែងផលប្រយោជន៍ទៀតឡើយ ។ ការតស៊ូ ឬ ចំណោទរបស់ជ្រូក និងរបស់មនុស្ស ត្រូវមានលំនាំប្រហាក់ប្រហែលគ្នា ។ តើបញ្ហាកិច្ចការមិនដូចគ្នាឬអ្វីទោះជានៅកន្លែងណាក៏ដោយ ។ និយាយមកដល់ត្រឹមណោះ គេសង្កេតឃើញថា ពូថងចង់បញ្ចេញទ្រឹស្តីរបស់គាត់ឲ្យភ្ញៀវទាំងអស់ស្ញើចនឹងគាត់ ។ តែគាត់សប្បាយខ្លាំងពេក រកនឹកគំនិតនោះមិនចេញ ។ ដោយដឹងខ្លួនថាគាត់និយាយបែបរអាក់រអួល ព្រោះសំដីរបស់គាត់ បែបមានផ្ទុផ្តាលែបខាយច្រើន គាត់ក៏បញ្ចប់សុន្ទរកថាដូចតទៅ ៖

“បើឯងមានសត្វដែលបំរើឯង នៅតែមានគំនិតប្រឆាំង” គាត់ស្រែកឡើង “យើងក៏មានគូលីយើងជាច្រើនដែលចេះតែតវ៉ាមិនចេះចប់” ពាក្យសំដីនេះ ធ្វើឲ្យអ្នកទាំងអស់សើចគឹលឡើង ។ ពូថងក៏បន្តសំដីទៅទៀត ដោយពោលពាក្យសរសើរពីជ្រូកដែលចេះឲ្យចំណីតិច តែចេះបង្ខំឲ្យសត្វធ្វើការ



ច្រើនព្រមទាំងចេះបង្រៀន កុំឲ្យបានការខ្ជះខ្ជាយ ដែលគាត់បានធ្វើការកត់សំគាល់ក្នុងភូមិនេះ ។

និយាយមកដល់ត្រឹមណោះ ពូថងក៏សុំឲ្យភ្ញៀវទាំងអស់ក្រោកឡើងឈរជើងពីរ - ព្រមទាំងសួរបញ្ជាក់ឲ្យដឹងថាតើកែវទាំងអស់មានស្រាពេញឬទេ រួចហើយគាត់ស្រែកឡើងថា ៖

“មិត្តជាទីរាប់អាន - ខ្ញុំសូមឲ្យមិត្តលើកកែវស្រានេះឡើង ហើយផឹកដើម្បីជាជោគជ័យ និងសេចក្តីចំរើនដល់ភូមិសប្រែង”

សំរែកហ៊ោនិងទន្រ្ទាំជើងក៏លាន់ឮឡើង ។ អាឈ្មុះស៊ឹងពោរពេញទៅដោយក្តីសប្បាយ និងរំភើប ។ វាដើរចេញពីតុតំរង់ទៅពូថង ។ ដល់ហើយវាយកកែវទៅចុងិចនឹងកែវពូថងរួច អកស្រាទាល់តែអស់គ្មានសល់ ។ លុះសម្លេងអ៊ូអរបានស្ងប់បន្តិច អាឈ្មុះដែលនៅខំឈរជើងពីរ ក៏ផ្តើមនិយាយទៅកាន់អង្គប្រជុំថា វាក៏ដូចជាពូថងដែរ វាមានពាក្យពីរ-បីម៉ាត់ នឹងនិយាយ ។

ជាទម្លាប់របស់វា អាឈ្មុះច្រើននិយាយខ្លីៗ តែចំចំណុចសំខាន់ៗ ។ វានិយាយថា វាក៏មានជំនឿថា ការយល់ច្រឡំកាលពីមុនមក ត្រូវបញ្ចប់នៅថ្ងៃនេះ ។ ជាយូរមកហើយ

ដែលចេះតែមានពាក្យចចាមអារាម ដែលបានប្រឌិតឡើង ដោយពួកសត្រូវ ក្នុងគោលបំណងចង់បង្ករឿងផ្សានាថា វា និងសហការីវា ជាអ្នកដើរបញ្ចុះបញ្ចូលគំនិតបដិវត្តន៍ ។ គេទាំងអស់ធ្លាប់ចោទថាវា ជាអ្នកផ្សាយគំនិតបំបះបំបោរសត្វនៅភូមិជិតខាង ។ វាគ្មានអ្វីធំជាងសេចក្តីពិតទេ ! គោលបំណងរបស់វា និងសត្វទាំងអស់ នៅភូមិសប្រែង គឺចង់តែរស់ដោយសន្តិភាព និងបានការទាក់ទង ជួញប្រែជាមួយអ្នកជិតខាងតែប៉ុណ្ណោះ ។ ភូមិនេះ ដែលវាមានសំណាងនិងកិត្តិយសបានមកត្រួតត្រា គឺជាភូមិដែលផ្សាយតែគំនិតឲ្យមានសហប្រតិបត្តិការ ។ ភូមិនេះមិនមែនជាកម្មសិទ្ធិរបស់វាតែម្នាក់ទេ គឺជាសម្បត្តិរួមនៃជ្រូកទាំងអស់ ។

វាបន្តទៀតថា វាមិនជឿថាសត្វទាំងអស់នៅតែមានការមិនទុកចិត្តលើវាទេ ។ តែទោះជាយ៉ាងណាក៏ដោយ វានឹងមានគំរោងការផ្លាស់ប្តូរតទៅទៀតក្នុងកិច្ចការរៀបចំភូមិ ដើម្បីឲ្យមានការទុកចិត្តកាន់តែច្រើនលើរូបវា ។ ដូចជាដឹងស្រាប់ហើយ សត្វទាំងឡាយនៅក្នុងភូមិនេះមានទម្លាប់អា-ក្រក់ដែលហៅគ្នាទៅវិញទៅមកថា " សមមិត្ត " ។ ពាក្យនេះត្រូវលុបចោល ។ វានៅមានទម្លាប់អាក្រក់ និងឥតប្រយោជន៍មួយទៀត គឺសត្វទាំងអស់ រាល់ថ្ងៃអាទិត្យ ត្រូវ



ដើរជាជួរទៅធ្វើការគោរពនៅមុខក្បាលខ្មោចអា " គំនិត " ដែលព្យួរជាប់នឹងបង្គោលក្នុងសួន ។ ទម្លាប់នេះត្រូវហាមមិនឲ្យមានតទៅទៀត ។ ឯក្បាលខ្មោចនោះក៏វាបានបញ្ជាឲ្យយកទៅកប់ចោលបាត់ទៅហើយ ។ ភ្ញៀវទាំងឡាយប្រហែលជាបានសង្កេតឃើញ ទង់ពណ៌បៃតងដែលបង្ហូតលើបង្គោលក្នុងសួនដែរ ។ ទង់នេះពីដើមមានសញ្ញាជើងសេះនិងស្នែងពណ៌ស ឥឡូវក៏បានលុបចោលនៅតែពណ៌បៃតងសុទ្ធ ។

អាឈ្មុះ នៅមានចំណុចមួយដែលចង់ធ្វើការកត់សំគាល់លើពាក្យសំដីដ៏ពីរោះ និងជាមិត្តភាពរបស់ពូថង ។ វាថា ពូថងនៅតែហៅឈ្មោះភូមិនេះជាភូមិ "វិមានសត្វ" ។ តែវាមិនបន្ទោសពូថងទេ ព្រោះនេះជាលើកដំបូងហើយដែលអាឈ្មុះបានប្រាប់គេទាំងអស់ឲ្យដឹងថាឈ្មោះភូមិ "វិមានសត្វ" ត្រូវលុបចោល ហើយឲ្យហៅថាភូមិសប្រែងវិញ ព្រោះឈ្មោះនេះជាឈ្មោះដើមហើយសមរម្យ ។ ដូច្នេះឈ្មោះនេះត្រូវហៅចាប់ពីថ្ងៃនេះទៅ ។

ថាហើយ អាឈ្មុះក៏បញ្ចប់សុន្ទរកថាដោយពោលពាក្យថា៖

“មិត្តជាទីរាប់អាន ខ្ញុំក៏បាន “តូស្ត” ជូនពួកឯងដែរ” ថា ហើយវាឱ្យគេក្រោកឈរ ហើយពោលថា៖

“ចាក់ស្រាឱ្យពេញកែវ មិត្តទាំងអស់គ្នា! នេះគឺតូស្ត របស់ខ្ញុំ សូមឱ្យជោគជ័យមានដល់ភូមិសម្រែង”! សម្រែក ហ៊ោកញ្ជ្រៀវក៏ឮឡើងម្តងទៀត ។ គេទាំងអស់នាំគ្នាអកស្រា ទាល់តែអស់គ្មានសល់មួយដំណក់ ។

សត្វទាំងអស់ស៊ូទ្រាំលួចមើលគេសប្បាយខាងក្នុង តែ វាដូចជាមានពិភាល់ក្នុងចិត្ត ព្រោះហាក់ដូចជានឹងមានវិបត្តិ មួយកើតឡើង ។ មុខជ្រូកទាំងអស់ហាក់ដូចជាមានសភាព ប្លែកខុសធម្មតា ។ មីកណ្តូបសេះខំប្រឹងបើកភ្នែកមើលមុខពី មួយទៅមួយ ។ វាដូចជាឃើញជ្រូកខ្លះមានមុខ ៥ ខ្លះទៀត ៤ ខ្លះទៀត ៣ ។ មុខមាត់ដ៏ចម្លែកនេះ ដល់មើលយូរៗ ទៅវាលាយចូលគ្នាឃើញតែមួយ ។ មួយស្របក់មកទើប សម្លេងខ្សឿវខ្សាវនោះស្ងាត់ឡើងវិញ ។ ជ្រូកនិងមនុស្សក៏ចាប់ ផ្តើមលេងបៀម្តងទៀតក្រោយពីបានធ្វើ “តូស្ត” រួច ។ ឃើញ ដូច្នោះហើយសត្វទាំងឡាយនាំគ្នាថយចេញពីបង្អួចហើយដើរ តំរង់ចូលក្រោលវិញ ។

គ្រាន់តែដើរបាន ២០ ម៉ែត្របុណ្ណោះ វាទាំងអស់ឈប់ ង៉ក់ ដោយឮសម្លេងឡូឡាចេញពីផ្ទះ ។ វារត់ទៅពួនលួច



មើលតាមចន្លោះបង្អួចម្តងទៀត ។ ម្តងនេះវាឃើញមនុស្ស និងជ្រូកឈ្លោះគ្នា ខ្លះស្រែកខ្លះវាយតុ ខ្លះសំឡក់សំឡឹងរក គ្នា ខ្លះប្រកែកជេរដាក់គ្នាទៅវិញទៅមក ។ រឿងហេតុនេះ ប្រហែលមកពី អាឈ្មុះ និងពូថង លេងបៀចង់បន្លំគ្នាទៅវិញ ទៅមកហើយមើលទៅ ! ។

វាឃើញមនុស្សស្រែកគំហកឡើងព្រមគ្នា ដាក់ឱ្យជ្រូក ព្រមទាំងបញ្ចេញកំហឹងរៀងៗខ្លួន ។ វាមិនដឹងថាជ្រូកនឹង ឆ្លើយតបទៅមនុស្សយ៉ាងម៉េចទេ ។ សត្វទាំងឡាយដែល កំពុងលួចមើល គ្រាន់តែសំឡឹងម្តងទៅមុខមនុស្ស ម្តងទៅ មុខជ្រូក ម្តងទៅជ្រូក ម្តងទៅមនុស្ស ចុះឡើងៗ ហើយទី បំផុតក៏នៅតែមិនដឹងថាមុខណាជាមុខណា ។ សត្វទាំងអស់ វង្វេងស្មារតីអស់ហើយ វាឈប់ឆ្ងល់ ឈប់ដឹង ឈប់ឮ ឈប់គិត ឈប់និយាយ ។ វាគ្រាន់តែដឹងថា វានៅមាន ដង្ហើមដកចេញចូល ហើយដឹងខ្លួនថាវានឹងធ្វើការតទៅទៀត មុននឹងដល់ថ្ងៃស្លាប់ ។

តែការណ៍ដែលវាដឹងច្បាស់ជាងអ្វីទាំងអស់ គឺមុខអ្នក កាន់អំណាចដូចៗគ្នា !!! ។

— ចប់ —

# ជីវប្រវត្តិអ្នកនិពន្ធ

លោក ជក អ័រវែល ( GEORGE ORWELL ) នាមដើម អេរិក ប្លែរ (Eric Blair) ជាជនជាតិអង់គ្លេស កើតនៅប្រទេសឥណ្ឌា នៅឆ្នាំ១៩០៣។ លោកបានសិក្សានៅអ៊ីតិន ( Eton ) ប្រទេសអង់គ្លេស ។ ពីឆ្នាំ ១៩២២ ទៅ ១៩២៨ លោកបានបំរើក្នុងក្រុមនគរបាល ( Indian Impérial Police ) នៅប្រទេសភូមា ។ ពីឆ្នាំ ១៩២៨ ទៅឆ្នាំ ១៩៣០ លោកត្រឡប់ទៅរស់នៅទីក្រុងប៉ារីស ហើយបន្ទាប់មកទៅបង្រៀននៅប្រទេសអង់គ្លេស ។

លោកត្រូវរបួសធ្ងន់នៅប្រទេសអេស្ប៉ាញក្នុងសង្គ្រាមស៊ីវិលនាឆ្នាំ ១៩៣៧ ( Spanish civil War ) ។ នៅសង្គ្រាមលោកលើកទីពីរលោកបានស្ម័គ្របំរើក្នុងអង្គការ B.B.C ។ ឆ្នាំ ១៩៤៣ លោកសរសេរក្នុងកាសែត “ Tribune ” ដែលជាកាសែតផ្នែកអក្សរសាស្ត្រនិងនយោបាយ ។ លោកជាអ្នកឆ្លើយឆ្លងកាសែត “ Observer ” នៅប្រទេសបារាំងនិងអាល្លឺម៉ង់ ។

លោកបានអនិច្ចកម្មនៅទីក្រុងឡុងនៅឆ្នាំ ១៩៥០ ។

លោកបាននិពន្ធរឿងជាច្រើនដូចជា : “ Down and out in Paris and London, Burmese Days, The Road to Wigan Pier, Coming Up for Air, Keep the Aspidistra Flying, Homage to Cataloma, Nineteen Eighty-Four, Allergyman's Daunghter, Inside the Whab and other Essays ”

រឿង “ Animal Farm ” ដែលត្រូវបានប្រែសម្រួលមកជាភាសាខ្មែរ

នេះ បានធ្វើឲ្យឈ្មោះលោក អ័រវែល ល្បីល្បាញលើឆាកអន្តរជាតិ ។

នៅពេលបោះពុម្ពលើកទីមួយកាលពីឆ្នាំ ១៩៤៥ សៀវភៅនេះបានលក់អស់ផាងមួយលានក្បាល ។

សព្វថ្ងៃនេះ លោក អ័រវែល មានឈ្មោះជាប់ក្នុងអក្សរសាស្ត្រអង់គ្លេសផ្នែករិះគន់អក្សរសាស្ត្រ ( Critique littéraire) និងនយោបាយ (Essai Politique ) ។ រឿងលោកជាច្រើន បានត្រូវគេយកទៅលេងជាល្ខោន ហើយជាពិសេសរឿង "Animal Farm" នេះ ។

រឿង "Animal Farm" បានចូលរោងពុម្ពជាច្រើនដង ដើម្បីឆ្លើយទៅនឹងសេចក្តីត្រូវការរបស់សាធារណជន ។ បើគិតពីឆ្នាំ ១៩៤៥ មកឆ្នាំ ១៩៧០ សៀវភៅនេះបានទទួលការបោះពុម្ពចំនួន ២៦ លើកហើយ ។